## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនប្លូអេចអរ ខនសាល់ធីង

## BlueHR Consulting Co., Ltd.

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦


| | | | |
|---|---|---|---|
| ស្រាវជ្រាវដោយ | | សាស្ត្រាចារ្យណែនាំ | |
| និស្សិតឈ្មោះ: | **មៀច សាម៉ឺឌី** | លោក | **ខិន ខណ្ណារ៉ា** |
| | **សោម ចិត្រា** | | |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ | **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា | ២០១២ |
| ជំនាន់ទី | **១៦** | ឆ្នាំសរសេរសារណា | ២០១៦ |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំបាទឈ្មោះ **មៀច សាម៉ឺឌី** និង **សោម ចិត្រា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ១៦ ឆ្នាំសិក្សា ២០១៥-២០១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។

សូមលំឱនកាយគោរព និង ថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះ៖

- លោកឪពុក **មៀច ម៉ុនថា** និង អ្នកម្តាយ **លាង ហុងឡាយ**
- លោកឪពុក **សោម សេ** និង អ្នកម្តាយ **ចាន់ សុផល**

ដែលបានផ្តល់កំណើត និង ខិតខំគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រលាញ់អនុគ្រោះ ព្រហ្មវិហារធម៌ និង អប់រំទូន្មានឱ្យប្រព្រឹត្តខ្លួនទៅតាមគន្លងធម៌ដើម្បីរស់នៅក្នុងសង្គម ព្រមទាំងទំនុកបម្រុងថវិកា ចាប់តាំងពីកម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សា ។ កូនសូមក្រាបប្រតិបត្តិ និង សម្តែងនូវកតញ្ញូធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះគុណណូបការៈរបស់លោកទាំងទ្វេរដែលមានមកលើកូន ។

- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀន សម្របសម្រួលដល់ពួកខ្ញុំបាទឱ្យទទួលបានជោគជ័យក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ។
- លោកគ្រូសាស្ត្រាចារ្យ **ឌិន ខណ្ណារ៉ា** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណានេះ ដែលលោកគ្រូបានណែនាំតម្រង់ទិស អំពីរបៀបរៀបចំបែបបទសរសេរសារណាឱ្យមានភាពល្អប្រសើ ដូចជាការកែសម្រួលនូវមាតិកា ឃ្លារឃ្លោង ការប្រមូលឯកសារ ជាពិសេសលោកតែងតែលើទឹកចិត្តឱ្យពួកយើងខ្ញុំខិតខំប្រឹងប្រែងសរសេរសារណានេះ បើទោះជាលោកត្រូវចំណាយពេលវេលា និង កម្លាំងកាយចិត្តរបស់គាត់ក៏ដោយ ។
- លោក **ស៊ឺ សុភក្តិ** ជានាយកក្រុមហ៊ុន និង លោក **ប៉ុខ សូឡីដេល្លា** ជាប្រធានគ្រប់គ្រងទូទៅនៃក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ដែលបានអនុញ្ញាតឱ្យក្រុមយើងខ្ញុំបានសរសេរអំពីក្រុមហ៊ុនរបស់លោក និង បានផ្តល់នូវឯកសារមួយចំនួនដែលពាក់ព័ន្ធលើប្រធានបទនេះរហូតទទួលបានជោគជ័យ ។

# អារម្ភកថា

យើងខ្ញុំរៀបចំចងក្រងសៀវភៅសារណានេះ ក្នុងគោលបំណងអភិវឌ្ឍនូវចំណេះដឹងដោយធ្វើការសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅទាំងទ្រឹស្តី និង ការអនុវត្តន៍ជាក់ស្តែងរបស់ក្រុមហ៊ុនមួយ ព្រមទាំងពង្រីកការយល់ដឹងឱ្យកាន់តែប្រសើរឡើង ។ ក្នុងនាមយើងខ្ញុំជាក្រុមនិស្សិតបានសិក្សាជំនាញនីតិសាស្ត្រអស់រយៈពេលបួនឆ្នាំកន្លងមកនេះ យើងខ្ញុំទាំងអស់គ្នាខិតខំព្យាយាមទាំងកម្លាំងកាយ កម្លាំងចិត្តក្នុងការរៀបចំចងក្រងសារណានេះឡើង ដោយមានសាស្ត្រាចារ្យជាអ្នកជួយសម្របសម្រួល និង ណែនាំ ។

សាកលភាវូបនីយកម្មតម្រូវឱ្យប្រទេសនីមួយៗក្នុងពិភពលោក ធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួនដើម្បីឱ្យមានការរីកចម្រើនទៅបាន គេតែងតែយកចិត្តទុកដាក់ជាចម្បងទៅលើវិស័យពាណិជ្ជកម្ម ធ្វើយ៉ាងណាឱ្យមានគុណភាព និង ស្ថេរភាព ។ ដើម្បីឱ្យសេដ្ឋកិច្ចជាតិកាន់តែមានភាពរឹងមាំ គេត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបង្កើនល្បឿនលើវិស័យឯកជន ។ យើងដឹងថាវិស័យឯកជន គឺជាស្នូលមួយដ៏សំខាន់នៅក្នុងការកសាងសេដ្ឋកិច្ចជាតិហើយប្រទេសជាតិអាចដំណើរការបានរលូនអាស្រ័យលើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុននីមួយៗ ។ ហេតុនេះទើបក្រុមយើងខ្ញុំសម្រេចចិត្តលើកយកប្រធានបទទាក់ទងនឹង **"ពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង"** ដែលជាក្រុមហ៊ុនឯកជនមួយសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ ដោយផ្សារភ្ជាប់ការអនុវត្តន៍ជាក់ស្តែងជាមួយនឹងវិធានគតិយុត្តិរបស់ខ្មែរយើង ។

យើងខ្ញុំសង្ឃឹមថា សារណានេះនឹងចូលរួមចំណែកជាជំនួយស្មារតីយល់ដឹងពីកិច្ចការធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនឯកជនមួយ ហើយក៏ដើម្បីជាស្ពាន និង ជាទុនសម្រាប់ជាឯកសារស្រាវជ្រាវដល់សិស្ស និស្សិតជំនាន់ក្រោយ និង មិត្តអ្នកអាន ពង្រឹងបន្ថែមនូវសមត្ថភាពរបស់ខ្លួន ។

ជាចុងក្រោយ យើងខ្ញុំសូមអភ័យទោសទុកជាមុនចំពោះរាល់កំហុសឆ្គងនៃការរៀបរៀងសៀវភៅនេះឡើងដោយអចេតនា ។ ទោះជាយ៉ាងនេះក្តី យើងខ្ញុំរងចាំទទួលការផ្តល់មតិយោបល់ និង ការរិះគន់ស្ថាបនាអំពីសំណាក់លោកសាស្ត្រាចារ្យ សិស្ស និស្សិត និង លោកអ្នកអានទាំងអស់ដោយក្តីសោមនស្សរីករាយ ដើម្បីឱ្យសៀវភៅនេះកាន់តែមានលក្ខណៈល្អប្រសើរឡើងថែមទៀត ។

# មាតិកា

ទំព័រ


សេចក្តីផ្តើម ........ ១
ជំពូកទី១ សញ្ញាណទូទៅនៃពាណិជ្ជកិច្ច និង កំណើតក្រុមហ៊ុន ........ ៤
១.១ សញ្ញាណនៃពាណិជ្ជកិច្ច ........ ៤
១.១.១ និយមន័យនៃពាណិជ្ជកិច្ច ........ ៤
១.១.២ ប្រភេទនៃពាណិជ្ជកិច្ច ........ ៥
១.២ ប្រវត្តិ និង គោលការណ៍របស់ក្រុមហ៊ុន ........ ៦
១.២.១ ប្រវត្តិក្រុមហ៊ុន ........ ៦
១.២.២ លក្ខន្តិកៈក្រុមហ៊ុន ........ ៨
ក. កម្មវត្ថុអាជីវកម្ម ........ ៩
ខ. ដើមទុន ........ ១០
គ. មហាសន្និបាតម្ចាស់ហ៊ុន និង ក្រុមប្រឹក្សាភិបាល ........ ១១
ឃ. ការរំលាយក្រុមហ៊ុន និង ការជម្រះបញ្ជី ........ ១៤
ង. ការដោះស្រាយវិវាទ និង ការផ្លាស់ប្តូរទម្រង់ក្រុមហ៊ុន ........ ១៦
១.២.៣ ការចុះបញ្ជីក្រុមហ៊ុន និង កាតព្វកិច្ចពន្ធដាររបស់ក្រុមហ៊ុន ........ ១៧
ក. ការចុះបញ្ជីក្រុមហ៊ុន ........ ១៧
ខ. កាតព្វកិច្ចពន្ធដាររបស់ក្រុមហ៊ុន ........ ១៨
ជំពូកទី២ វិធានគតិយុត្តិនៃពាណិជ្ជកិច្ចដែលក្រុមហ៊ុនអនុវត្ត ........ ១៩
២.១ ការបង្កើតកិច្ចសន្យា ........ ១៩
២.១.១ ការព្រមព្រៀង ........ ២០
២.១.២ សមត្ថភាពនៃភាគី ........ ២២
២.១.៣ កម្មវត្ថុនៃកិច្ចសន្យា ........ ២២

ក. កិច្ចសន្យាសេវាកម្មជ្រើសរើសបុគ្គលិក ........ ២៣
ខ. កិច្ចសន្យាសេវាកម្មប្រឹក្សាច្បាប់ការងារ ........ ២៤
២.១.៤ តម្លៃតបស្នង ........ ២៤
២.២ អានុភាពនៃកិច្ចសន្យា ........ ២៥
២.២.១ សិទ្ធិរបស់ភាគី ........ ២៦
ក. សិទ្ធិរបស់ភាគីទទួលសេវាកម្ម ........ ២៦
ខ. សិទ្ធិរបស់ភាគីផ្តល់សេវាកម្ម ........ ២៧
២.២.២ ភាតព្វកិច្ចរបស់ភាគី ........ ២៨
ក. ភាតព្វកិច្ចរបស់ភាគីទទួលសេវាកម្ម ........ ២៩
ខ. ភាតព្វកិច្ចរបស់ភាគីផ្តល់សេវាកម្ម ........ ៣០
សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍ ........ ៣៣
១. សេចក្តីសន្និដ្ឋាន ........ ៣៣
២. ការផ្តល់អនុសាសន៍ ........ ៣៤
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

សេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្នប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ដែលនាំឱ្យមាននៅលំហូរវិនិយោគពីបរទេស ការនាំចេញនាំចូល និង សកម្មភាពពាណិជ្ជកិច្ចដ៏ទៃទៀត ។ តាមរយៈប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី សកម្មភាពពាណិជ្ជកិច្ចបានស្ដែងឡើងតាមរយៈការទិញលក់ សកម្មភាពនៃសហគ្រាសជួល សហគ្រាសយកកម្រៃជើងសារ សហគ្រាសដឹកជញ្ជូន ប្រតិបត្តិការនៃធានាគារប្ដូររូបិយវត្ថុ ការិយាល័យសម្របសម្រួលកិច្ចការ សេវាទីភ្នាក់ងារ និង សេវាអន្តរការជាដើម ។ តាមរយៈការសិក្សាបានបង្ហាញថា ការធ្វើពាណិជ្ជកិច្ចតាមយៈការផ្ដល់សេវាកម្ម គឺជាពាណិជ្ជកិច្ចកំពុងតែពេញនិយម ។ ជាក់ស្ដែងមានក្រុមហ៊ុនផ្ដល់សេវាកម្មខាងផ្នែកប្រកាសពន្ធ សវនកម្ម ប្រឹក្សាច្បាប់ និង សេវាកម្មពិគ្រោះយោបល់ផ្នែកធនធានមនុស្ស ។

ដើម្បីឱ្យវិស័យពាណិជ្ជកម្មមានភាពល្អប្រសើទើបយើងសង្កេតឃើញថា ប្រទេសកម្ពុជាបានបង្កើតវិធានគតិយុត្តិពាក់ព័ន្ធនឹងពាណិជ្ជកម្ម ក្នុងនោះមានក្រមរដ្ឋប្បវេណី ច្បាប់ស្ដីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ឆ្នាំ ១៩៩៥ និងច្បាប់ស្ដីពីវិសោធនកម្ម ឆ្នាំ ១៩៩៩ និង ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥ ជាអាទិ៍ សុទ្ធតែមានសារៈសំខាន់សម្រាប់ពាណិជ្ជករ ក្នុងការធ្វើពាណិជ្ជកិច្ចរបស់ខ្លួន ជាពិសេសជួយឱ្យការធ្វើពាណិជ្ជកិច្ចរបស់ពួកគាត់មានភាពស្របច្បាប់ ត្រូវបានច្បាប់ការពារ និង ជាវិធានក្នុងជួយដោះស្រាយបញ្ហានៅពេលដែលមានវិវាទកើតឡើង ។

ក្នុងការអនុវត្តន៍ជាក់ស្ដែងចំពោះការធ្វើពាណិជ្ជកិច្ចរបស់ពាណិជ្ជករ ជាពិសេសក្រុមហ៊ុនអាជីវកម្ម អាចនឹងមានភាពខុសប្លែកពីគ្នាមួយចំនួនទៅនឹងវិធានច្បាប់ ដោយសារតែចំណុចមួយចំនួនច្បាប់មិនបានចែងលម្អិត ឬការមិនបានស្វែងយល់អំពីច្បាប់របស់ពាណិជ្ជករ និង តំណាងក្រុមហ៊ុន ។ បញ្ហាដែលអាចនឹងកើតមានចំពោះសកម្មភាពពាណិជ្ជកិច្ច ភាគច្រើនពាក់ព័ន្ធនឹងដំណើរការនៃការបង្កើតក្រុមហ៊ុន និង ការធ្វើពាណិជ្ជកិច្ចរបស់ពាណិជ្ជករជាមួយនឹងអតិថិជនរបស់ខ្លួន ជាពិសេសការបង្កើតកិច្ចសន្យា ការអនុវត្តន៍កិច្ចសន្យា និង ការដោះស្រាយវិវាទ ។ តើការធ្វើពាណិជ្ជកិច្ចមានដំណើរការយ៉ាងដូចម្ដេច ? ហើយមានវិធានគតិយុត្តិណាខ្លះដែលត្រូវយកមកអនុវត្តក្នុងសកម្មភាពពាណិជ្ជកិច្ចខាងលើនេះ ?

អ្នកសិក្សា និង ពាណិជ្ជករភាគច្រើនមិនបានដឹងច្បាស់ឡើយអំពីការប្រព្រឹត្តទៅរបស់ក្រុមហ៊ុនស្របច្បាប់មួយ ។ ដូច្នេះការស្វែងយល់អំពីការអនុវត្តន៍ជាក់ស្ដែង គឺជាកត្តាមិនអាចខ្វះបាន

ឡើយសម្រាប់អ្នកសិក្សា ក៏ដូចជាអ្នកដែលមានបំណងចង់ប្រកបអាជីវកម្ម ។ គោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីបង្ហាញឱ្យអ្នកសិក្សាស្រាវជ្រាវបានយល់ដឹងអំពី ការធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនមួយ សញ្ញាណទូទៅនៃពាណិជ្ជកិច្ច ការបង្កើតក្រុមហ៊ុន និង វិធានគតិយុត្តិនៃពាណិជ្ជកិច្ចដែលក្រុមហ៊ុនយកមកអនុវត្ត ។

ការស្រាវជ្រាវនេះ ផ្តោតសំខាន់ទៅលើ "**ពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនប្ល៊ូអេចអ ខនសាល់ធីង**" យើងនឹងលើកយកសេវាកម្មរបស់ក្រុមហ៊ុន កិច្ចសន្យារបស់ក្រុមហ៊ុនជាមួយអតិថិជន លក្ខន្តិកៈរបស់ក្រុមហ៊ុន និង វិធានគតិយុត្តិដែលក្រុមហ៊ុនយកមកអនុវត្ត ។

ជាទូទៅការសិក្សាស្រាវជ្រាវគួរតែផ្តល់នូវអត្ថប្រយោជន៍សម្រាប់អ្នកស្រាវជ្រាវ សិស្ស និស្សិត និង សាធារណៈជនទូទៅ ។ ចំពោះការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "**ពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនប្ល៊ូអេចអ ខនសាល់ធីង**" នឹងផ្តល់អត្ថប្រយោជន៍ដល់សាមីខ្លួនដែលជាអ្នកស្រាវជ្រាវ សិស្ស និស្សិត និង សាធារណៈជនទូទៅដូចជា៖

- យល់ដឹងអំពីការធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនប្ល៊ូអេចអ ខនសាល់ធីង
- យល់ដឹងអំពីការអនុវត្តន៍វិធានគតិយុត្តិក្នុងក្រុមហ៊ុន និង កិច្ចសន្យាពាណិជ្ជកម្មមួយចំនួន
- ទទួលបាននូវបទពិសោធន៍ជាក់ស្តែងពីក្រុមហ៊ុន
- ទុកជាជាស្នាដៃ ក៏ដូចជាឯកសារសម្រាប់អ្នកជំនាន់ក្រោយយកមកធ្វើការស្រាវជ្រាវ ។

ដើម្បីឱ្យការស្រាវជ្រាវនេះទទួលបានជោគជ័យ ពួកយើងបានធ្វើការស្នើរសុំឯកសារពីក្រុមហ៊ុនប្ល៊ូអេចអ សាល់ធីង ដូចជាលក្ខន្តិកៈក្រុមហ៊ុន កិច្ចសន្យាសេវាកម្មរបស់ក្រុមហ៊ុន និង ធ្វើការសម្ភាសន៍ជាមួយថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនផ្ទាល់ ។ ក្រៅពីនេះយើងខ្ញុំក៏ធ្វើការដកស្រង់ឯកសារច្បាប់មួយចំនួនរបស់ព្រះរាជាណាចក្រកម្ពុជាយើងផងដែរ បន្ថែមពីលើនេះ គេហទំព័ររបស់ក្រុមហ៊ុនប្ល៊ូអេចអ ខនសាល់ធីង និង សៀវភៅស្នាដៃរបស់សាស្ត្រាចារ្យមួយចំនួន រួមទាំងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សុទ្ធសឹងតែជាប្រភពដ៏សំខាន់សម្រាប់ការស្រាវជ្រាវមួយនេះ ។

នៅក្នុងប្រធានបទ "**ពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនប្ល៊ូអេចអ ខនសាល់ធីង**" សូមធ្វើការបែងចែកជាដំណាក់កាលសំខាន់ៗដូចតទៅ៖

- **សេចក្តីផ្តើម**
- **ជំពូកទី ១៖ សញ្ញាណទូទៅនៃពាណិជ្ជកិច្ច និង កំណើតក្រុមហ៊ុន** នឹងធ្វើការបកស្រាយពីរចំណុចសំខាន់ៗគឺ (១.១) សញ្ញាណនៃពាណិជ្ជកិច្ច ដែលក្នុងចំណុចនេះមានពន្យល់អំពីនិយមន័យនៃពាណិជ្ជកិច្ច និង ប្រភេទនៃពាណិជ្ជកិច្ច និង (១.២) ប្រវត្តិ និង គោលការណ៍របស់ក្រុមហ៊ុន ដោយមានការពន្យល់អំពី ប្រវត្តិក្រុមហ៊ុន លក្ខន្តិកៈក្រុមហ៊ុន ការចុះបញ្ជីក្រុមហ៊ុន និង កាតព្វកិច្ចពន្ធដារបស់ក្រុមហ៊ុន ។
- **ជំពូកទី ២៖ វិធានគតិយុត្តិនៃពាណិជ្ជកិច្ចដែលក្រុមហ៊ុនអនុវត្ត** ដែលនឹងធ្វើការបកស្រាយពីរចំណុចសំខាន់ៗគឺ (២.១) ការបង្កើតកិច្ចសន្យា ហើយក្នុងចំណុចនេះមានពន្យល់អំពីការព្រមព្រៀង សមត្ថភាពនៃភាគី កម្មវត្ថុនៃកិច្ចសន្យា និង តម្លៃតបស្នង និង (២.២) អានុភាពនៃកិច្ចសន្យា ដែលមានការពន្យល់អំពីសិទ្ធិរបស់ភាគី និង កាតព្វរបស់ភាគី ។
- **សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍**

# ជំពូកទី ១

# សញ្ញាណទូទៅនៃពាណិជ្ជកិច្ច

# និង

# កំណើតក្រុមហ៊ុន

# ជំពូកទី ១

# សញ្ញាណទូទៅនៃពាណិជ្ជកិច្ច និង កំណើតក្រុមហ៊ុន

ជាគោលការណ៍ ពាណិជ្ជកិច្ចត្រូវបានធ្វើឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបុគ្គលទាំងនេះយកពាណិជ្ជកិច្ចធ្វើជាមុខរបររបស់ខ្លួនជាប្រចាំដើម្បីស្វែងរកប្រាក់ចំណេញ ។ បើយើងក្រឡេកមើលសកម្មភាពក្នុងការស្វែងរកប្រាក់ចំណេញ ត្រូវបានលេញឡើងតាមរយៈសកម្មភាពដែលមានលក្ខណៈជាគ្រួសារ និង ក្រុមហ៊ុន ។ យើងកត់សម្គាល់ឃើញថា នៅក្នុងការធ្វើពាណិជ្ជកិច្ចដែលផ្តល់ភាពងាយស្រួល និង មានស្ថេរភាព គឺការធ្វើពាណិជ្ជកិច្ចដោយនីតិបុគ្គល ។ នីតិបុគ្គលត្រង់ចំណុចនេះ សំដៅទៅលើនីតិបុគ្គលដែលស្វែងរកប្រាក់ចំណេញ ហើយជាទូទៅយើងហៅថាក្រុមហ៊ុន ។

ដើម្បីឱ្យយល់កាន់តែច្បាស់អំពីសញ្ញាណទូទៅនៃពាណិជ្ជកិច្ច និង កំណើតក្រុមហ៊ុននៅក្នុងជំពូកទី ១ នេះមានលើកយកមកបកស្រាយនូវចំណុចពាក់ព័ន្ធនឹង **សញ្ញាណនៃពាណិជ្ជកិច្ច ប្រវត្តិ និង គោលការណ៍របស់ក្រុមហ៊ុន ។**

## ១.១ សញ្ញាណនៃពាណិជ្ជកិច្ច

សកម្មភាពមួយចំនួនត្រូវបានច្បាប់ចាត់ទុកថាជាពាណិជ្ជកិច្ច ដោយឡែកសកម្មភាពមួយចំនួនទៀតមិនត្រូវបានចាត់ទុកថា ជាពាណិជ្ជកិច្ចនោះទេ ។

តើពាណិជ្ជកិច្ច មានអត្ថន័យយ៉ាងដូចម្តេច? ហើយសកម្មភាពណាខ្លះ ដែលត្រូវបានចាត់ថាជាពាណិជ្ជកិច្ច និង សកម្មភាពណាខ្លះដែលមិនត្រូវបានចាត់ទុកថាជាពាណិជ្ជកិច្ច?

តទៅនេះយើងសូមធ្វើការលើកយក **និយមន័យពាណិជ្ជកិច្ច និង ប្រភេទនៃពាណិជ្ជកិច្ច** មកបង្ហាញជូនដូចខាងក្រោម៖

### ១.១.១ និយមន័យនៃពាណិជ្ជកិច្ច

ការស្វែងយល់ពីអត្ថន័យនៃពាណិជ្ជកិច្ច គឺជាចំណុចសំខាន់ដើម្បីឈានទៅយល់លើប្រធានបទនេះទាំងមូល ។ ពាណិជ្ជកិច្ចត្រូវបានឱ្យនិយមន័យដោយច្បាប់ខ្មែរដូចតទៅ៖

**ពាណិជ្ជកិច្ច ជាសកម្មភាពទិញលក់ទំនិញ ឬសេវាដែលត្រូវបានអនុវត្តជាប្រចាំក្នុងគោលដៅធ្វើការដោះដូរ និង ស្វែងរកចំណេញ**[1] ។ បន្ថែមពីលើនេះ ច្បាប់ខ្មែរស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម មាត្រា ២ ចំណុច ឈ វិញ ពាក្យថា**ពាណិជ្ជកម្ម** ត្រូវបកស្រាយឱ្យបានទូលំទូលាយដើម្បីគ្របដណ្តប់លើធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មទោះបីជាមានកិច្ចសន្យា ឬគ្មានកិច្ចសន្យាក៏ដោយ ។ ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មមានដូចជា កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬការផ្លាស់ប្តូរទំនិញ ឬសេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ លក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬសម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់ វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬសម្បទាន ក្រុមហ៊ុនចម្រុះ និង ប្រភេទផ្សេងៗទៀត នៃសហប្រតិបត្តិការឧស្សាហកម្ម ឬពាណិជ្ជកម្ម និង ការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវគោក និង ផ្លូវទឹក[2] ។

### ១.១.២ ប្រភេទនៃពាណិជ្ជកិច្ច

មាត្រា ២ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៥ និង ច្បាប់ស្តីវិសោធនកម្ម ឆ្នាំ១៩៩៩ បានកំណត់អំពីសកម្មភាពដែលត្រូវចាត់ទុកថាជាពាណិជ្ជកិច្ចមានដូចជា៖

- ការទិញដើម្បីលក់ទៅវិញ គិតបញ្ចូលទាំងក្នុងវិស័យអចលនទ្រព្យ
- រាល់សកម្មភាពនៃសហគ្រាសជួល សហគ្រាសការណកម្ម សហគ្រាសយកកម្រៃជើងសារ សហគ្រាសដឹកជញ្ជូន សហគ្រាសបោះពុម្ពផ្សាយ និង សេវាដទៃទៀត
- ប្រតិបត្តិការនៃធនាគា ប្តូររូបិយវត្ថុ
- ការផ្តល់សេវាអន្តរការី សេវាទីភ្នាក់ងារ ការិយាល័យសម្របសម្រួលកិច្ចការ សេវាវប្បធម៌ និង ការចាត់ចែងនូវទស្សនីយភាពជាសាធារណ:
- ប្រតិបត្តិការនៃសហគ្រាសសំណង់ ការទិញ ឬការជួលនាវាដឹកជញ្ជូនក្នុងប្រទេស ឬក្រៅប្រទេស ការដឹកជញ្ជូនតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស
- ការធានារ៉ាប់រងគ្រប់ប្រភេទ
- អាជីវកម្មនេសាទ អាជីវកម្មព្រៃឈើ និង រ៉ែ ។

---

[1] មាត្រា ២ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៥ និង ច្បាប់ស្តីពីវិសោធនកម្ម ឆ្នាំ១៩៩៩ ។

[2] សិក្ខាប័ននីតិពាណិជ្ជកម្មរបស់លោកសាស្ត្រាចារ្យ ជិន វណ្ណារ៉ា បោះពុម្ពឆ្នាំ ២០១៣ ទំព័រ៤៦ ។

ចំណែកឯមាត្រា ៣ នៃច្បាប់នេះដដែលក៏បានកំណត់សកម្មភាពមួយចំនួនដែលមិនចាត់ទុកថាជាពាណិជ្ជកិច្ចដែរ គឺរាល់សកម្មភាពដែលមានជាអាទិ៍៖

- ការផលិតដែលមិនមែនសម្រាប់លក់ទៅវិញ
- ការផលិត ឬសេវាទាំងឡាយ ដែលមានលក្ខណៈជាគ្រួសារ
- ការផលិតសិល្បៈសុទ្ធសាធ
- ការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួន ឬដោយសមាគមស្របច្បាប់

ម្យ៉ាងវិញទៀត មិនចាត់ទុកថាជាពាណិជ្ជកិច្ចទេ ផលិតករ ឬកសិករទាំងឡាយដែលធ្វើសកម្មភាពមានលក្ខណៈជាគ្រួសារ (មាត្រា ៤ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៥ និង ច្បាប់ស្តីពីវិសោធនកម្ម ឆ្នាំ១៩៩៩) ។

## ១.២ ប្រវត្តិ និង គោលការណ៍របស់ក្រុមហ៊ុន

ជាគោលការណ៍ ដើម្បីបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត បុគ្គលដែលមានបំណងធ្វើជាសមាជិកត្រូវសហការគ្នាបង្កើតលក្ខន្តិកៈ ហើយចុះហត្ថលេខារៀងៗខ្លួន ។[៣] ម្យ៉ាងវិញទៀត ដើម្បីឱ្យក្រុមហ៊ុនមានបុគ្គលភាពគតិយុត្តិ ក្រុមហ៊ុនត្រូវធ្វើការចុះបញ្ជី និង មានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋទៀតផង ។ តទៅនេះ យើងសូមលើកយកប្រវត្តិក្រុមហ៊ុន លក្ខន្តិកៈ ការចុះបញ្ជី និង កាតព្វកិច្ចពន្ធដារបស់ក្រុមហ៊ុនប៊្លូអេចអ ខនសាល់ធីងមកបង្ហាញជូន ។

### ១.២.១ ប្រវត្តិក្រុមហ៊ុន

នៅឆ្នាំ ១៩៩៩ ក្រុមហ៊ុន**ប៊្លូតិចណូឡូជី** ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់សេវាកម្មលើដំណោះស្រាយបច្ចេកវិទ្យា ។ ដោយសារតែមានភាពរីកចម្រើនបច្ចេកវិទ្យា ជាពិសេសលើផ្នែកតម្រូវការធនធានមនុស្ស ស្ថាប័ននេះក៏សម្រេចចិត្តបង្កើតក្រុមហ៊ុនថ្មីមួយ គឺក្រុមហ៊ុន**ប៊្លូអេចអ ខនសាល់ធីង** ក្នុងឆ្នាំ ២០១៣ ។

ក្រុមហ៊ុន **ប៊្លូអេចអ ខនសាល់ធីង** គឺជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមួយ ដែលមានឯករាជ្យភាពពីក្រុមហ៊ុន ប៊្លូតិចណូឡូជី ហើយត្រូវបានបង្កើតឡើងនៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៣ តាមរយៈប្រកាសទទួលស្គាល់របស់ក្រសួងពាណិជ្ជកម្មលេខ **Co. ២៣២១ KH/២០១៣** ។

[៣] មាត្រា ៨២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៧ ។

លើសពីនេះទៅទៀតក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ត្រូវបានបង្កើតឡើងដើម្បីផ្តល់សេវាកម្មពិគ្រោះយោបល់ផ្នែកធនធានមនុស្ស ដល់ក្រុមហ៊ុនទូទាំងប្រទេសកម្ពុជា និង ក្រុមហ៊ុនក្រៅប្រទេសផងដែរ ។ គំរូយុទ្ធសាស្ត្រអាជីវកម្មរបស់ក្រុមហ៊ុន គឺជាការរួមបញ្ចូលនៃសេវាកម្មធនធានមនុស្សប្រកបដោយប្រសិទ្ធិភាពខ្ពស់ និង ដំណោះស្រាយផ្នែកបច្ចេកវិទ្យាដែលគួរជាទីទុកចិត្តបាន ទៅកាន់អតិថិជនជាមួយនឹងតម្លៃសមរម្យ ។ បន្ថែមពីលើនេះ ក្រុមហ៊ុនក៏មានក្រុមការងារដែលមានវិជ្ជាជីវៈប្រកបដោយភាពស្ទាត់ជំនាញ និង មានចំណេះដឹងខ្ពស់ពាក់ព័ន្ធនឹងវិស័យនេះ ។ ជាងនេះទៅទៀតក្រុមហ៊ុនក៏មានការតាំងចិត្តខ្ពស់ ក្នុងការផ្តល់នូវដំណោះស្រាយផ្នែកធនធានមនុស្សដល់អតិថិជនជាមួយវិធីសាស្ត្រដែលមានប្រសិទ្ធិភាពបំផុត ដើម្បីសម្រេចបាននូវបំណងប្រាថ្នារបស់អតិថិជន ។

ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងក៏បានកំណត់នូវទស្សនៈវិស័យ បេសកម្ម ក៏ដូចជា អត្តសញ្ញាណរបស់ខ្លួនផងដែរ ហើយចំណុចទាំងនេះមានដូចខាងក្រោម៖

- **ទស្សនៈវិស័យរបស់ក្រុមហ៊ុន៖** ជាអ្នកផ្តល់នូវសេវាកម្មគ្រប់គ្រងលើការបើកប្រាក់ខែ និង សេវាកម្មធនធានមនុស្ស ដែលជាជម្រើសសម្រាប់អតិថិជន និង ដៃគូរជំនួញ ។
- **បេសកម្មរបស់ក្រុមហ៊ុន៖** គឺដើម្បីផ្តល់នូវសេវាកម្មដែលលឿនគួរជាទីទុកចិត្ត និង ប្រកបដោយគុណភាពទាក់ទងនឹងសេវកម្មគ្រប់គ្រងការបើកប្រាក់ខែបុគ្គលិក សេវាកម្មគ្រប់គ្រងបុគ្គលិកដោយប្រយោល សេវាកម្មជ្រើសរើសបុគ្គលិក និង សេវកម្មប្រឹក្សាផ្នែកធនធានមនុស្សទាំងក្នុងប្រទេស និង ក្រៅប្រទេស ។
- **អត្តសញ្ញាណរបស់ក្រុមហ៊ុន៖** ដើម្បីឱ្យអតិថិជនបង្កើននូវផលិតភាពអាជីវកម្មរបស់ខ្លួនដោយប្រើប្រាស់នូវសេវាកម្មដ៏កម្រ និង ភាពស្ទាត់ជំនាញក្នុងការដោះស្រាយបញ្ហាផ្នែកធនធានមនុស្ស និង ជួយដល់ភាគីដែលពាក់ព័ន្ធឱ្យអស់ពីសមត្ថភាព ។

ក្រុមហ៊ុននេះមានទីតាំងផ្ទះលេខ ៧៣BG ផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកងទី ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ មានគេហទំព័ររបស់ក្រុមហ៊ុន www.blue-hr.com. និង លេខទូស័ព្ទទំនាក់ទំនងក្រុមហ៊ុន ០២៣ ២២៤ ២៨២ ។

### ១.២.២ លក្ខន្តិកៈក្រុមហ៊ុន

លក្ខន្តិកៈរបស់ក្រុមហ៊ុនមួយត្រូវថែងនូវលក្ខខណ្ឌដូចខាងក្រោម[៩]៖

- នាមករណ៍របស់ក្រុមហ៊ុន
- ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- កម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន និង ការកំណត់នូវអាជីវកម្មដែលក្រុមហ៊ុននោះយកធ្វើពាណិជកិច្ច ។ កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនអាចមានមួយ ឬច្រើនប្រភេទដែលមិនផ្ទុយទៅនឹងបញ្ញាត្តិណាមួយនៃច្បាប់ ។
- ដើមទុនត្រូវប្រកាសជារូបិយវត្ថុជាតិ ។
- ចំណាត់ប្រភេទ និង ចំនួនអតិបរមានៃភាគហ៊ុនព្រមទាំងតម្លៃចារឹកលើប័ណ្ណភាគហ៊ុនដែលត្រូវបានអនុញ្ញាតឱ្យបោះចេញដោយក្រុមហ៊ុននោះ ។
- ក្នុងករណីក្រុមហ៊ុនត្រូវបានអនុញ្ញាតឱ្យបោះប័ណ្ណភាគហ៊ុនលើសពីមួយ ប្រភេទហ៊ុននោះ លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវថែងចំនួនភាគហ៊ុនអតិបរមា និង តម្លៃចារឹកលើប័ណ្ណភាគហ៊ុន ហើយត្រូវរៀបរាប់ពីសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និង លក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃប័ណ្ណភាគហ៊ុននោះ ។
- ក្នុងករណីប្រភេទភាគហ៊ុនត្រូវបោះជាស៊េរី លក្ខន្តិកៈក្រុមហ៊ុននោះត្រូវអនុញ្ញាតឱ្យអភិបាលកំណត់ចំនួនភាគហ៊ុននៃស៊េរីនីមួយៗ ដើម្បីកំណត់ប្លង់បែងចែកស៊េរីនីមួយៗ ហើយឈានទៅកំណត់សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និង លក្ខខណ្ឌដែលភ្ជាប់ទៅនឹងស៊េរីនីមួយៗនោះ ។
- ក្នុងករណីការបោះចេញ ការផ្ទេរ ឬការកាន់កាប់ប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវហាមឃាត់ ពេលនោះត្រូវមានរបាយការណ៍ពីប្រសិទ្ធិភាព និង មានរបាយការណ៍ពីការកម្រិតនោះ ។
- ឈ្មោះ និង អាសយដ្ឋានពិតប្រាកដរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ ។
- ចំនួនអភិបាល ឬចំនួនអប្បបរមា និង អតិបរមានៃអភិបាលរបស់ក្រុមហ៊ុននោះ ។

[៩] មាត្រា ៩៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ ។

ម្យ៉ាងវិញទៀតលក្ខន្តិកៈត្រូវបញ្ចូលផងដែរ នូវរាល់ចំណុចផ្សេងទៀតតាមការចាំបាច់[៥] ។

ដោយឡែក នៅក្នុងលក្ខន្តិកៈរបស់**ក្រុមហ៊ុន ប៊្លូអេចអ ខនសាល់ធីង** ចែកចេញជា ១១ ប្រការ តែយើងខ្ញុំសូមលើកយកតែចំណុចមួយចំនួនតែប៉ុណ្ណោះមកបង្ហាញ ។ ចំណុចដែលត្រូវលើកយកមកនោះមានដូចជា **កម្មវត្ថុអាជីវកម្ម ដើមទុន មហាសន្និបាតម្ចាស់ហ៊ុន ក្រុមប្រឹក្សាភិបាល ការរំលាយក្រុមហ៊ុន ការជម្រះ ការដោះស្រាយវិធាន ការផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន ការចុះបញ្ជីក្រុមហ៊ុន និង កាតព្វកិច្ចពន្ធដាររបស់ក្រុមហ៊ុន ។**

### ក. កម្មវត្ថុអាជីវកម្ម

ក្រុមហ៊ុនប៊្លូអេចអ ខនសាល់ធីងមានកម្មវត្ថុអាជីវកម្មនៅក្នុងកម្ពុជា និង នៅប្រទេសដទៃទៀតដោយចំពោះ ឬមិនចំពោះដូចតទៅ[៦]៖

- ពាណិជ្ជកម្ម៖ ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ-នាំចូលឱសថ សម្ភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
- ការជួលដាក់ឃ្លាំនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសម្ភារៈ ទំនិញគ្រប់ប្រភេទ
- ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
- ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ
- មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
- បើកសាលារៀន
- ភ្នាក់ងារពាណិជ្ជកម្ម-តំណាងពាណិជ្ជកម្ម
- សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- សេវារកការងារជូនអតិថិជនធ្វើក្នុង និង ក្រៅប្រទេស
- សេវាផ្នែកពត៌មានវិទ្យា
- សេវាផ្សាយពាណិជ្ជកម្ម
- បោះពុម្ពផ្សាយ
- ផលិតខ្សែភាពយន្ត វីដេអូ CD

[៥] មាត្រា ៩៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ។
[៦] ប្រការ ២ នៃលក្ខន្តិកៈក្រុមហ៊ុនប៊្លូអេចអ ខនសាល់ធីង ។

- ដឹកជញ្ជូន៖ ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ
- សេវាយកកម្រៃជើងសារលើការដឹកជញ្ជូន
- សាងសង់ ជួសជុលអគារ ស្ពាន ផ្តល់-ស្ថាបត្យកម្ម រចនាប្លង់ ត្រួតពិនិត្យ និង សិក្សាគម្រោងប្លង់សំណង់គ្រប់ប្រភេទ
- ទេសចរណ៍៖ សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត
- វិនិយោគលើវិស័យកសិកម្ម៖ ដាំដំណាំ ចិញ្ចឹមសត្វ
- វិនិយោគលើវិស័យឧស្សាហកម្ម៖ រោងចក្រ សិប្បកម្ម

បើទោះបីជាកម្មវត្ថុដែលមានចែងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនមានចែងច្រើនក៏ដោយ តែការធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនបច្ចុប្បន្ន គឺផ្តោតទៅលើសេវាកម្ម **ពិគ្រោះយោបល់ផ្នែកធនធានមនុស្ស** ដែលក្នុងសេវាកម្មនេះមានសេវាកម្ម **ជ្រើសរើសបុគ្គលិក និង ប្រឹក្សាច្បាប់ការងារ ។**

### ខ. ដើមទុន

យោងតាមក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៧ មាត្រា ៨៣ នីតិបុគ្គលទទួលខុសត្រូវមានកម្រិតត្រូវមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមានតម្លៃមិនតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល ។ សម្រាប់ដើមទុនរបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង គឺមានដើមទុនអប្បបរមា ២០.០០០.០០០ (ម្ភៃលាន) រៀលហើយអាចត្រូវបានប្រែប្រួលអាស្រ័យលើស្ថានភាពប្រតិបត្តិការរបស់ក្រុមហ៊ុន ដូច្នេះដើមទុនក្រុមហ៊ុនអាចត្រូវបានបង្កើន ឬបន្ថយតាមលក្ខខណ្ឌដូចខាងក្រោម៖

#### ខ.១ ការបង្កើនដើមទុន

ដើមទុនរបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង អាចត្រូវបានបង្កើនតាមរយៈ[៧]៖

- បង្កើតបន្ថែមនូវភាគហ៊ុនថ្មីៗ ជាសាច់ប្រាក់ ឬជាវត្ថុ
- បង្វិលបញ្ចូលមួយភាគ ឬទាំងស្រុងនៃមូលនិធិបម្រុងមកក្នុងដើមទុន
- តម្លើងតម្លៃនៃភាគហ៊ុននីមួយៗ ដែលមានរួចហើយ
- តាមគ្រប់វិធីដទៃទៀតដែលច្បាប់អនុញ្ញាត ។

[៧] ប្រការ ៥.២ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។

ការបង្កើនដើមទុនតាមវិធីតម្លើងតម្លៃនៃភាគហ៊ុនដែលមានរួចហើយ និង ដែលត្រូវបង់ចូលមកក្នុងក្រុមហ៊ុនជាសាច់ប្រាក់នេះ ត្រូវតែមានសេចក្ដីសម្រេចដោយឯកច្ឆ័ន្ទពីម្ចាស់ហ៊ុន ។ ចំណែកឯការបង្កើនដើមទុនដោយដាក់បន្ថែមភាគទុនជាវត្ថុ ភាគទុនជាវត្ថុនេះត្រូវតែបានវាយតម្លៃដោយស្នងការភាគទុន កាលណាតម្លៃភាគទុននេះលើសពី ៥០% នៃដើមទុន ។ បើតម្លៃភាគទុនជាវត្ថុនេះមានតម្លៃតិចជាង ៥០% នៃដើមទុនក្រុមហ៊ុន ការវាយតម្លៃភាគទុននេះអាចធ្វើឡើងដោយត្រឹមតែម្ចាស់ហ៊ុនទាំងអស់គ្នា ។ ក្នុងករណីបង្កើនដើមទុនដោយភាគទុនជាសាច់ប្រាក់ រាល់ម្ចាស់ហ៊ុនលើកលែងតែមានការប្រកែកត្រឹមត្រូវ មានសិទ្ធិជ្រើសរើសយកចំនួនភាគទុនថ្មីទៅតាមសមាមាត្រនៃភាគទុនដែលខ្លួនមាន ទៅតាមបែបបទមួយកំណត់ដោយសេចក្ដីសម្រេចនៃមហាសន្និបាតម្ចាស់ហ៊ុន ។

### ខ.២ ការន្ថយដើមទុន

ដើមទុនអាចត្រូវបានបន្ថយ អាស្រ័យដោយសេចក្ដីសម្រេចនៃមហាសន្និបាតម្ចាស់ហ៊ុនដែលសម្រេចទៅតាមលក្ខខណ្ឌបញ្ញត្តិនៃច្បាប់ ក៏ប៉ុន្តែការបន្ថយដើមទុនមិនត្រូវឱ្យប៉ះពាល់ដល់សមភាពនៃម្ចាស់ហ៊ុន ឬក៏មិនត្រូវឱ្យនៅតិចជាងពាក់កណ្ដាលនៃដើមទុនចុះបញ្ជីដំបូង និង ទាបជាងដើមទុនកំណត់ដោយច្បាប់ ។ ការបន្ថយដើមទុនត្រូវតែអនុញ្ញាតដោយមហាសន្និបាតម្ចាស់ហ៊ុន[៨] ។

## គ. មហាសន្និបាតម្ចាស់ហ៊ុន និង ក្រុមប្រឹក្សាភិបាល

នៅក្នុងដំណើរការរបស់ក្រុមហ៊ុនមួយ ទាមទារយ៉ាងចាំបាច់នូវរចនាសម្ព័ន្ធនៃការគ្រប់គ្រងក្រុមហ៊ុនដើម្បីធានានូវប្រតិបត្តិការឱ្យមានស្ថេរភាព និង ល្អប្រសើរឡើង ។ យ៉ាងដូច្នេះហើយបានជាក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងក៏មិនភ្លេចផងដែរនូវរចនាសម្ព័ន្ធនៃការគ្រប់គ្រងនេះ ។ តទៅនេះយើងសូមលើកយកតែក្បាលម៉ាស៊ីន ដែលជាផ្នែកមួយនៃរចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង គឺមហាសន្និបាតម្ចាស់ហ៊ុន និង ក្រុមប្រឹក្សាភិបាល ។

### គ.១ មហាសន្និបាតម្ចាស់ហ៊ុន

មហាសន្និបាតម្ចាស់ហ៊ុន គឺជាការប្រជុំពេញអង្គរបស់នីតិបុគ្គលសាជីវកម្មដែលធ្វើឡើងរវាងសមាជិកភាគហ៊ុនដើម្បីអនុម័តកិច្ចការសំខាន់ៗរបស់នីតិបុគ្គលនោះ ឬជាអង្គការសម្រេចកិច្ចការ

[៨] ប្រការ ៥.២ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។

សំខាន់ៗរបស់នីតិបុគ្គលសាជីវកម្មដែលចូលរួមដោយសមាជិក ដើម្បីសម្រេចកិច្ចការសំខាន់ៗរបស់នីតិបុគ្គលនោះ[៩] ។

ការប្រជុំរបស់មហាសន្និបាតធ្វើឡើងយ៉ាងហោចណាស់ ១ (មួយ) ឆ្នាំម្តង ហើយអាចកោះប្រជុំពេលណាក៏បាន ដោយសម្លេងភាគច្រើនរបស់ក្រុមប្រឹក្សាភិបាល ឬដោយប្រធានក្រុមប្រឹក្សាភិបាល ឬដោយសម្លេងភាគច្រើននៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុន ឬដោយសវនករ ។ កូរ៉ុមនៃមហាសន្និបាតម្ចាស់ហ៊ុនត្រូវបានកំណត់ចំនួនសម្លេងភាគច្រើនលើសពីពាក់កណ្តាល នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុន ។ ក្នុងករណីមហាសន្និបាតលើកទី១ មិនបានទទួលកូរ៉ុមគ្រប់គ្រាន់តាមចំនួនលើសពីពាក់កណ្តាលនៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនទេ មហាសន្និបាតលើកទី ២ ត្រូវធ្វើឡើងយ៉ាងហោចណាស់ ២០ (ម្ភៃ) ថ្ងៃក្រោយ ហើយកូរ៉ុមត្រូវបានកំណត់សម្លេងយ៉ាងតិច១/៣ (មួយភាគបី) នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុន[១០] ។

នៅពេលដែលមានមហាសន្និបាត ម្ចាស់ហ៊ុនទាំងអស់មានសិទ្ធិពេញលេញក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តទោះបីគេមានឋានៈណាក៏ដោយ ឬមានភាគហ៊ុនប៉ុន្មានក៏ដោយ ។ ការសម្រេចរបស់មហាសន្និបាតអាចយកជាការបាន លុះត្រាតែមានសម្លេងភាគច្រើនលើសពី ៥១ (ហាសិបមួយ) ភាគរយនៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលមានវត្តមានក្នុងអង្គប្រជុំ[១១] ។ ម្ចាស់ហ៊ុនម្នាក់ៗអាចប្រគល់សិទ្ធិជូនម្ចាស់ហ៊ុនម្នាក់ទៀតធ្វើជាតំណាងរបស់ខ្លួន ដោយមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវ[១២] ។

### គ.២ ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលជាបុគ្គលមួយក្រុម ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយម្ចាស់ហ៊ុនតាមរយៈមហាសន្និបាតម្ចាស់ហ៊ុន ហើយក្រុមប្រឹក្សាភិបាលមានសិទ្ធិអំណាចអនុវត្តភារកិច្ចដូចមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុន ។ ប្រការ ១០ នៃលក្ខន្តិកៈរបស់ក្រុមហ៊ុន ប្លូអេចអ ខនសាល់ធីង បានចែងអំពីក្រុមប្រឹក្សាភិបាលរបស់ខ្លួនដូចតទៅ៖

---

[៩] សន្ធានុក្រមផ្នែករដ្ឋប្បវេណី លេខ១២០ ។

[១០] ប្រការ ៥.៣ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។

[១១] ប្រការ ៥.៣.៥ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។

[១២] ប្រការ ៥.៣.៧ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។

- **ការជ្រើសតាំងអភិបាល៖** អភិបាលត្រូវបានជ្រើសតាំងតាមសេចក្តីសម្រេចនៃម្ចាស់ហ៊ុនទាំងឡាយ ដែលតំណាងឱ្យសម្លេងភាគច្រើនលើសពី ៥១ (ហាសិបមួយ) ភាគរយនៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលមានវត្តមានក្នុងអង្គប្រជុំ ហើយដែលមានអាណត្តិមិនកំណត់ ។ ប៉ុន្តែក្នុងករណីចាំបាច់ និង សមស្របអភិបាលអាចត្រូវបានជ្រើសតាំងឡើងវិញ ។
- **ការបាត់បង់សមាជិកភាព៖** អភិបាលអាចបាត់បង់សមាជិកភាពរបស់ខ្លួនតាមរយៈការលាលែងពីតំណែងដោយខ្លួនឯង ការដកហូតពីតំណែង ដោយសេចក្តីសម្រេចនៃម្ចាស់ហ៊ុនទាំងឡាយ ដែលតំណាងឱ្យសម្លេងភាគច្រើនលើសពី ៥១ (ហាសិបមួយ) ភាគរយនៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលមានវត្តមានក្នុងអង្គប្រជុំ ។ ក្នុងករណីអភិបាលលាលែងពីតំណែងត្រូវតែជូនដំណឹងយ៉ាងតិច ៣ (បី) ខែមុន ដោយលិខិតអនុសិដ្ឋមានបញ្ជាក់ការបានទទួលផ្ញើរជូនម្ចាស់ហ៊ុនគ្រប់រូប ។
- **ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល៖** ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងយ៉ាងតិចម្តងរៀងរាល់ ៣ (បី) ខែ ។ ការប្រជុំអាចប្រព្រឹត្តទៅបានលុះតែមានកូរ៉ុមចូលរួមប្រជុំចំនួនភាគច្រើនរបស់ភិបាលនៅក្នុងអង្គប្រជុំ ។ ប៉ុន្តែក្នុងករណីចាំបាច់ចំនួនអភិបាលចំនួន ១/៣ (មួយភាគបី) ឬប្រធានក្រុមប្រឹក្សាភិបាល មានសិទ្ធិកោះប្រជុំមហាសន្និបាតរបស់ក្រុមប្រឹក្សាភិបាល ដោយធ្វើលិខិតអញ្ជើញផ្ញើជូនទៅអភិបាលទាំងអស់យ៉ាងយូរបំផុត ២០ (ម្ភៃ) ថ្ងៃមុនការប្រជុំ ។ រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាចមានអានុភាពទៅបានលុះត្រាតែមានសម្លេងគាំទ្រភាគច្រើននៃចំនួនអភិបាលទាំងឡាយដែលមានវត្តមានក្នុងអង្គប្រជុំ ។
- **សិទ្ធិរបស់ប្រធានក្រុមប្រឹក្សាភិបាល៖** ប្រធានក្រុមប្រឹក្សាភិបាលត្រូវបានប្រគល់អំណាចជូនយ៉ាងទូលំទូលាយ ដើម្បីធ្វើសកម្មភាពរាល់កិច្ចការចាត់ចែងគ្រប់យ៉ាងដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុនដូចជា ចុះហត្ថលេខាលើរាល់កិច្ចការដែលស្ថិតក្នុងរង្វង់ក្របខណ្ឌនៃកម្មវត្ថុរបស់ក្រុមហ៊ុន និង អាចតែងតាំងអាណត្តិគាហកម្នាក់ ឬច្រើននាក់ឱ្យទទួលចាត់ចែងនូវកម្មវត្ថុណាមួយ ឬកម្មវត្ថុមួយចំនួនដោយមានការកំណត់ជាក់លាក់ជាជំនួសខ្លួន និង ក្រោមការទទួលខុសត្រូវរបស់ខ្លួន ។ ក៏ប៉ុន្តែចំពោះកិច្ចការមួយចំនួនដូចជា ការទិញ ការលក់ ការដោះដូរអចលទ្រព្យ ឬមូលនិធិពាណិជ្ជកម្ម ការចុះកិច្ចសន្យាខ្ចីបុលក្នុងនាមក្រុមហ៊ុន ការខ្ចីឥណទានពីធនាគារ ការធ្វើអ៊ីប៉ូតែកលើអសង្ហារឹមភ័ណ្ឌរបស់ក្រុមហ៊ុន ការបញ្ចាំមូលនិធិពាណិជ្ជកម្ម ឬការចូលរួមសហការក្នុងការបង្កើតក្រុមហ៊ុននានា ការកែប្រែលក្ខន្តិកៈ ត្រូវតែមានការអនុញ្ញាតដោយសេចក្តីសម្រេច ជាឯកច្ឆ័ន្ទនៃម្ចាស់ហ៊ុនទាំងឡាយ ។ ការចុះកិច្ច

សន្យារបស់ប្រធានក្រុមប្រឹក្សាភិបាលជាមួយតតិយជន លើកិច្ចការទាំងឡាយដែលស្ថិតនៅក្រៅកម្មវត្ថុអាជីវកម្មត្រូវចាត់ទុកជាមោឃៈ ហើយការប្រព្រឹត្តល្មើសនេះត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះបច្ច័យទាំងឡាយដែលមានកើតឡើងដោយសារកំហុសទាំងនេះ និង អាចត្រូវបានដកហូតពីមុខតំណែងចេញពីប្រធានក្រុមប្រឹក្សាភិបាល ។

- **ការតែងតាំងក្រុមប្រឹក្សាភិបាល** ត្រូវបានតែងតាំងជាអភិបាលនៃក្រុមហ៊ុនសម្រាប់អាណត្តិមានរយៈពេលមិនកំណត់ឆ្នាំចំពោះ[១៣]៖

**១. លោក ផ្លុង លីឡឿន ពាណិជ្ជករ សញ្ជាតិ ខ្មែរ ជាប្រធានក្រុមប្រឹក្សាភិបាល**

**២. លោក ស៊ឺ សុភក្តិ ពាណិជ្ជករ សញ្ជាតិ ខ្មែរ ជាអភិបាល**

**៣. លោក ឈុន ផៃនិត ពាណិជ្ជករ សញ្ជាតិ ខ្មែរ ជាអភិបាល**

រាល់អភិបាលដែលបានតែងតាំងនេះ សន្យាថានឹងលះបង់ពេលវេលាចាំបាច់សម្រាប់ធ្វើកិច្ចការរបស់ក្រុមហ៊ុន ស្មោះត្រង់ជាមួយក្រុមហ៊ុន និង ធ្វើការងារដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន ។

### ឃ. ការរំលាយក្រុមហ៊ុន និង ការជម្រះបញ្ជី

តាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ចិរវេលាសកម្មភាពរបស់ក្រុមហ៊ុនមានចំនួន ៩៩ (កៅសិបប្រាំបួន) ឆ្នាំ ដែលត្រូវផ្ដើមគិតចាប់ពីថ្ងៃបានចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម លើកលែងតែមានករណីរំលាយក្រុមហ៊ុនមុនកាលកំណត់ ឬការពន្យាពេលបន្ត ។ យ៉ាងតិចណាស់មួយឆ្នាំមុនការផុតកំណត់នៃចិរវេលា ៩៩ (កៅសិបប្រាំបួន) ឆ្នាំនេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំឱ្យមានការប្រជុំមហាសន្និបាតនៃម្ចាស់ហ៊ុនដើម្បីសម្រេចទៅតាមលក្ខខណ្ឌទាំងឡាយនៃកូរ៉ុម និង ភាគច្រើនដែលតម្រូវចាំបាច់សម្រាប់កែប្រែលក្ខន្តិកៈ ថាតើក្រុមហ៊ុនត្រូវរំលាយ ឬត្រូវពន្យាពេលបន្ត ។ បើប្រធានក្រុមប្រឹក្សាភិបាលមិនបានកោះប្រជុំធ្វើសេចក្តីសម្រេចនេះទេ សម្លេង ១/៣ (មួយភាគបី) នៃអំណាចបោះឆ្នោតម្ចាស់ហ៊ុនទាំងអស់ ក្រោយពេលដែលបានដាក់ពាក្យសុំឱ្យប្រជុំតាមរយៈលិខិតអនុសិដ្ឋិ ហើយមិនបានទទួលផលតាមសំណូមពរនោះអាចស្នើសុំទៅប្រធានតុលាការមានសមត្ថ-

[១៣]ប្រការ ១០.៣ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។

កិច្ច តែងតាំងអាណត្តិគាហករបស់តុលាការ ឱ្យទទួលបន្ទុករៀបចំការប្រជុំក្នុងនាមម្ចាស់ហ៊ុនទាំងអស់ដើម្បីធ្វើសេចក្តីសម្រេចអំពីបញ្ហានេះ[១៤] ។

### ឃ.១ ក្រុមហ៊ុនអាចត្រូវបាន រំលាយដោយមូលហេតុ[១៥]

- ក្នុងករណីរយៈពេល ៩៩ (កៅសិបប្រាំបួន) ឆ្នាំ នៃប្រតិបត្តិការក្រុមហ៊ុនត្រូវបានបញ្ចប់
- ក្នុងករណីមានការខាតបង់ ៣/៤ (បីភាគបួន) នៃដើមទុនក្រុមហ៊ុន ប្រសិនបើស្ថានការណ៍ក្រុមហ៊ុនមិនអាចធ្វើឱ្យមានប្រក្រតីភាពឡើងវិញបានក្នុងចិរវេលា ១(មួយ)ឆ្នាំ
- តាមសេចក្តីសម្រេចសមូហភាពនៃម្ចាស់ហ៊ុន ទោះបីមិនមានការខាតបង់ដើមទុន
- ក្រុមហ៊ុនអាចត្រូវបានរំលាយផងដែរ តាមផ្លូវតុលាការដោយមូលហេតុត្រឹមត្រូវ ។

មរណៈភាព អសមត្ថភាព ការហាមឃាត់ ធនក្ស័យ ឬភាគហ៊ុនហោចរបស់ម្ចាស់ហ៊ុនណាម្នាក់ដែលជារូបវន្តបុគ្គល ព្រមទាំងការកែទម្រង់ឡើងវិញ ឬការជម្រះតាមផ្លូវតុលាការរបស់ម្ចាស់ហ៊ុនណាមួយ ដែលជានីតិបុគ្គលមិនបណ្តាលឱ្យក្រុមហ៊ុនរំលាយឡើយ ។ ក៏ប៉ុន្តែបើព្រឹត្តិការណ៍ណាមួយក្នុងចំណោមព្រឹត្តិការណ៍ខាងលើបានកើតមានឡើងចំពោះអភិបាល នោះនាំឱ្យអភិបាលនោះត្រូវបានបញ្ឈប់ពីតំណែងជាអភិបាលភ្លាម[១៦] ។

### ឃ.២ ការជម្រះបញ្ជី[១៧]

កាលណាក្រុមហ៊ុនផុតចិរវេលានៃប្រតិបត្តិការរបស់ខ្លួន ឬក្នុងករណីមានការរំលាយក្រុមហ៊ុនដោយមូលហេតុណាមួយដូចចំណុចខាងលើ ក្រុមហ៊ុនត្រូវមានកាតព្វកិច្ចធ្វើការជម្រះ ។ នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនមានអត្ថិភាពសម្រាប់តម្រូវការជម្រះ រហូតដល់ពេលបិទការជម្រះនេះ និង លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ។ និទ្ទេសន៍ក្រុមហ៊ុនស្ថិតក្នុងការជម្រះ ព្រមទាំងនាមនៃអ្នកជម្រះត្រូវមានចែងលើរាល់លិខិតស្នាម និង ឯកសារទាំងឡាយដែលផ្សាយចេញពីក្រុមហ៊ុន ការជម្រះត្រូវធ្វើឡើងដោយអ្នកជម្រះម្នាក់ ឬច្រើននាក់ដែលតែងតាំងដោយម្ចាស់ហ៊ុនតំណាងឱ្យសម្លេងភាគច្រើនលើសពី ៥១ (ហាសិបមួយ) ភាគរយ នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែល

[១៤] ប្រការ ៤ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។
[១៥] ប្រការ ៩.២ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។
[១៦] ប្រការ ៩.៣ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។
[១៧] ប្រការ ៩.២ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។

មានវត្តមានក្នុងអង្គប្រជុំ ។ អ្នកជម្រះអាចត្រូវបានជ្រើសរើសក្នុងចំណោមម្ចាស់ហ៊ុន ឬយកអ្នកដំទៃក្រៅពីនេះ ។ សូមបញ្ជាក់ផងដែរថា ការជម្រះត្រូវអនុវត្តឱ្យស្របច្បាប់ហើយផលពិតបានមកពីការជម្រះដំបូង ត្រូវប្រើប្រាស់សម្រាប់សងវិញទឹកប្រាក់ភាគហ៊ុនដែលមិនទាន់បានសង ។ ចំណែកដែលសល់លើសពីនោះនឹងត្រូវបែងចែកជូនម្ចាស់ហ៊ុនទាំងអស់ ទៅតាមសមាមាត្រនៃភាគហ៊ុនដែលម្នាក់ៗមាន ។

## ង. ការដោះស្រាយវិវាទ និង ការផ្លាស់ប្តូរទម្រង់ទ្រាយក្រុមហ៊ុន

### ង.១ ការដោះស្រាយវិវាទ[18]

រាល់បណ្តឹងជំនួសមុខ ឬវិវាទដែលអាចកើតឡើងរវាងម្ចាស់ហ៊ុននឹងម្ចាស់ហ៊ុន ឬរវាងម្ចាស់ហ៊ុនជាមួយនឹងអភិបាលនៅក្នុងចិរវេលាក្រុមហ៊ុន ឬនៅក្នុងរយៈពេលជម្រះត្រូវធ្វើការដោះស្រាយដោយការសម្រុះសម្រួលគ្នាក្នុងក្រុមហ៊ុន ។ ក្នុងករណីមិនអាចសម្រុះសម្រួលគ្នាបានទេនឹងត្រូវដាក់ជូនទៅស្ថាប័នផ្សះផ្សារវិវាទពាណិជ្ជកម្ម ឬប្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។

### ង.២ ការផ្លាស់ប្តូរទម្រង់ទ្រាយក្រុមហ៊ុន[19]

ក្រុមហ៊ុនអាចត្រូវបានផ្លាស់ប្តូរទម្រង់ទ្រាយពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដោយសេចក្តីសម្រេចរបស់មហាសន្និបាតម្ចាស់ហ៊ុនតំណាងឱ្យសម្លេងភាគច្រើនលើសពី ៥១ (ហាសិបមួយ) ភាគរយនៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលមានវត្តមានក្នុងអង្គប្រជុំ ។ ការផ្លាស់ប្តូរនេះអាចធ្វើទៅបានតែនៅក្រោយពេលដែលក្រុមហ៊ុនសម្រេចបានតុល្យការនៃការិយបរិច្ឆេទ ២ (ពីរ) ឆ្នាំ រួចមកហើយ ។ រាល់សេចក្តីសម្រេចផ្លាស់ប្តូរទម្រង់ទ្រាយក្រុមហ៊ុនត្រូវតែមានធ្វើជាមុននូវរបាយការណ៍លើស្ថានភាពរបស់ក្រុមហ៊ុន ទោះបីជាក្រុមហ៊ុនមិនទាន់មានសវនករនៅឡើយក៏ដោយ ។ បន្ថែមពីលើនេះទៀត បើនៅក្រោយរយៈពេល ២ (ពីរ) ឆ្នាំ ចំនួនម្ចាស់ហ៊ុនកើនលើសពី ៣០ (សាមសិប) រូបនោះក្រុមហ៊ុនក៏អាចផ្លាស់ប្តូរទម្រង់ទ្រាយទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបានដែរ ។

[18] ប្រការ ៩.៥ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។
[19] ប្រការ ៩.៤ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។

## ១.២.៣ ការចុះបញ្ជីក្រុមហ៊ុន និង ការតព្វកិច្ចពន្ធដារបស់ក្រុមហ៊ុន

ក្រោយពីមានការព្រមព្រៀងគ្នាក្នុងកាបង្កើតក្រុមហ៊ុនរួចហើយ ក្រុមហ៊ុននោះត្រូវធ្វើការចុះបញ្ជី និង ត្រូវបង់ពន្ធជូនរដ្ឋដែលនេះជាកាតព្វកិច្ចមិនអាចខ្វះបានឡើយដើម្បីឱ្យក្រុមហ៊ុននោះមានភាពស្របច្បាប់ និង ត្រូវបានច្បាប់ការពារ ។ ខាងក្រោមនេះយើងសូមធ្វើការពន្យល់អំពីការចុះបញ្ជីក្រុមហ៊ុន និង ការតព្វកិច្ចពន្ធដារបស់ក្រុមហ៊ុន ។

### ក. ការចុះបញ្ជីក្រុមហ៊ុន

ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៥ និង ច្បាប់ស្តីពីវិសោធនកម្មឆ្នាំ១៩៩៩ មាត្រា ១២ បានចែងថា ពាណិជ្ជករ និង ក្រុមហ៊ុនទាំងឡាយដែលមានគ្រឹះស្ថានរបស់ខ្លួនសាខាបុត្រសម្ព័ន្ធ ឬទីភ្នាក់ងាររបស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីនេះ លើកលែងតែពាណិជ្ជករដែលមិនជាប់ពន្ធលើប្រាក់ចំណេញ ។ រយៈពេលយ៉ាងតិចបំផុត ១៥ (ដប់ប្រាំ)ថ្ងៃមុនពេលចាប់ផ្តើមធ្វើពាណិជ្ជកម្មរបស់ខ្លួនពាណិជ្ជករត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នាកន្លែងដែលខ្លួនធ្វើអាជីវកម្ម[២០] ។ ម្យ៉ាងវិញទៀតមាត្រា ៤៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧បានបញ្ញាត្តថានីតិបុគ្គលត្រូវបានបង្កើតឡើងដោយការចុះបញ្ជីនៅកន្លែងដែលមានទីតាំងនៃទីស្នាក់ការកណ្តាលរបស់នីតិបុគ្គលនោះ ។ យោងតាមចំណុចខាងលើនេះបានបញ្ជាក់ឱ្យឃើញថា រាល់ក្រុមហ៊ុនទាំងអស់ត្រូវធ្វើការចុះបញ្ជីដើម្បីឱ្យនីតិបុគ្គលនោះទទួលបាននូវនីតិបុគ្គលភាពហើយអ្នកដែលមានកាតព្វកិច្ចធ្វើការចុះបញ្ជីគឺជាស្ថាបនិក ឬអភិបាល ឬអាណត្តិគាហកដែលមានសមត្ថភាពតាមផ្លូវច្បាប់ត្រូវទៅចុះឈ្មោះ និង តម្កល់ទុកលក្ខន្តិកៈក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មតាមការបញ្ញាត្តិនៃច្បាប់ ។ ស្ថាបនិក ឬអភិបាល ឬអាណត្តិគាហក មានសិទ្ធិ និង សមត្ថភាពពេញលេញតាមផ្លូវច្បាប់ដើម្បីបំពេញទម្រង់ការនៃការផ្សព្វផ្សាយដែលច្បាប់បានបញ្ញាត្តិ និង ជាពិសេសដើម្បីចុះហត្ថលេខាលើសេចក្តីប្រកាសចុះផ្សាយក្នុងសារពត៌មាន[២១] ។ ក្រុមហ៊ុនប៊្លូអេចអ ខនសាល់ធីងត្រូវបានចុះនៅក្រសួងពាណិជ្ជកម្មនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣ ដែលការចុះបញ្ជីនេះបានគោរពទៅតាមបែបបទ និង នីតិវិធីដែលបានរៀបរាប់ខាងលើនេះ ។

[២០] មាត្រា ១៤ ថ្មី នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៥ និង ច្បាប់ស្តីពីវិសោធនកម្ម ឆ្នាំ១៩៩៩ ។
[២១] ប្រការ ១១.១ នៃលក្ខន្តិកៈក្រុមហ៊ុនប៊្លូអេចអ ខនសាល់ធីង ។

### ខ. កាតព្វកិច្ចពន្ធដាររបស់ក្រុមហ៊ុន

បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុង ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ហើយក៏ត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃក្រោយពីការផ្លាស់ប្តូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវ-កម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស[២២] ។

កាតព្វកិច្ចបង់ពន្ធរបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងមានពីរធំៗគឺ កាតព្វកិច្ចបង់ពន្ធប្រចាំឆ្នាំ និង ប្រចាំខែ ។ និយាយអំពីការបង់ពន្ធប្រចាំឆ្នាំមានចំនួនពីរទៀត គឺពន្ធលើប្រាក់ចំណេញ ដែលក្រុមហ៊ុនត្រូវបង់ចំនួន ២០ (ម្ភៃ) ភាគរយ[២៣] និង ពន្ធបាតតង់អាស្រ័យទៅលើប្រតិបត្តិការរបស់ក្រុមហ៊ុន ។ ដោយឡែកកាតព្វកិច្ចបង់ពន្ធប្រចាំខែវិញមានចំនួន ៣ (បី) គឺពន្ធកាត់ទុកចំនួន ១០ (ដប់) ភាគរយ[២៤] ពន្ធអាករលើតម្លៃបន្ថែម ១០ (ដប់) ភាគរយ ពន្ធប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ចំនួន ១ (មួយ) ភាគរយ និង ពន្ធលើប្រាក់បៀវត្សរបស់បុគ្គលិកដែលមានប្រាក់ខែចាប់ ៨០០០០០ (ប្រាំបី) សែនរៀល ត្រូវជាប់ពន្ធ ១ (មួយ) ឬ៥ (ប្រាំ) ភាគរយអាស្រ័យទៅលើចំនួនប្រាក់ខែបុគ្គលិក ។

រាល់សោហ៊ុយចំណាយលើពន្ធអាករផ្សេងៗ និង កម្រៃនានាដែលកើតមានមុនពេលក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្ម ត្រូវជាបន្ទុករបស់ម្ចាស់ហ៊ុនទាំងអស់គ្នាទៅតាមសមាមាត្រនៃភាគហ៊ុនរបស់ខ្លួន ។ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីក្រុមហ៊ុនទៅ រាល់សោហ៊ុយចំណាយទាំងអស់នឹងត្រូវទទួលបន្ទុកដោយក្រុមហ៊ុនដែលនឹងធ្វើការរម្លស់នៅមុនពេលបែងចែកប្រាក់ចំណេញ និង យ៉ាងយូរបំផុតរម្លស់ឱ្យអស់នៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ[២៥] ។

[២២] មាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ ។
[២៣] មាត្រា ២០ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧ បានបញ្ញត្តថា អត្រាពន្ធលើប្រាក់ចំណេញមាន ២០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល ។
[២៤] មាត្រា ២៥ ចំណុច ខ នៃច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧ បានបញ្ញត្តថា ពន្ធកាត់ទុកត្រូវមានអត្រាចំនួន ១០ ភាគរយ ចំពោះប្រាក់ចំណូលពីការជួលចលន ឬអចលនវត្ថុ ។
[២៥] ប្រការ ១១.៣ នៃលក្ខន្តិកៈក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។

# ជំពូកទី ២
# វិធានគតិយុត្តិនៃពាណិជ្ជកិច្ច
# ដែលក្រុមហ៊ុនអនុវត្ត

# ជំពូកទី ២

# វិធានគតិយុត្តិនៃពាណិជ្ជកិច្ចដែលក្រុមហ៊ុនអនុវត្ត

អាជីវកម្មរបស់ក្រុមហ៊ុនស្តែងឡើងតាមរយៈពាណិជ្ជកិច្ច ដែលក្រុមហ៊ុនអនុវត្តជាប្រចាំ ។ ពាណិជ្ជកិច្ចដែលក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងអនុវត្តជាប្រចាំត្រូវបានធ្វើឡើងតាមរយៈកិច្ចសន្យារវាងភាគីប្លូអេចអ ខនសាល់ធីងជាមួយនឹងភាគីអតិថិជន ហើយកិច្ចសន្យាទាំងនោះមានដូចជា កិច្ចសន្យាជ្រើសរើសបុគ្គលិក និង កិច្ចសន្យាប្រឹក្សាច្បាប់ការងារ ។

នៅក្នុងជំពូកទី ២ នេះយើងសូមលើកយកវិធានគតិយុត្តិដែលពាក់ព័ន្ធនឹង**គោលការណ៍ទូទៅនៃកិច្ចសន្យា និង អានុភាពនៃកិច្ចសន្យា** មកធ្វើការបកស្រាយ ។

## ២.១ ការបង្កើតកិច្ចសន្យា

**កិច្ចសន្យា** គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច[២៦] ។ លើសពីនេះទៅទៀត សេចក្តីព្រៀងច្បាប់ស្តីកិច្ចសន្យាពាណិជ្ជកម្ម មាត្រា ៤ ចំណុច ខ បានឱ្យនិយមន័យនៃកិច្ចសន្យាពាណិជ្ជកម្មថា៖ **កិច្ចសន្យាពាណិជ្ជកម្ម សំដៅដល់បុគ្គលពីរនាក់ ឬច្រើនដែលមានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចពាណិជ្ជកម្ម ។** កាតព្វកិច្ចពាណិជ្ជកម្ម សំដៅដល់ទំនាក់ទំនងគតិយុត្តិរវាងបុគ្គលពីរនាក់ ឬច្រើននាក់ ដោយឱ្យបុគ្គលនីមួយៗដែលបានបំពេញកាតព្វកិច្ចទៅវិញទៅមក ឱ្យភាគីមួយចំនួនតាមការព្រមព្រៀងកំណត់ដោយភាគីម្ខាងទៀត (មាត្រា ៤ ចំណុច ក នៃសេចក្តីព្រៀងច្បាប់ស្តីកិច្ចសន្យាពាណិជ្ជកម្ម) ។ នៅក្នុងការបង្កើតកិច្ចសន្យានេះ នឹងបង្ហាញពាក់ព័ន្ធនឹងការបង្កើតកិច្ចសន្យាពាណិជ្ជកម្មជាពិសេសហើយនឹងធ្វើការស្វែងយល់អំពីវិធានច្បាប់នៃពាណិជ្ជកិច្ចដែលបានអនុវត្តនៅក្នុងក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។ តើមានលក្ខខណ្ឌអ្វីខ្លះដើម្បីបង្កើតកិច្ចសន្យា?

ជាគោលការណ៍ លក្ខខណ្ឌដើម្បីបង្កើតកិច្ចសន្យាមួយមានដូចជា **ការព្រមព្រៀង សមត្ថភាពនៃភាគី កម្មវត្ថុនៃកិច្ចសន្យា និង តម្លៃតបស្នង ។**

[២៦] សន្ធានុក្រមផ្នែករដ្ឋប្បវេណី ចំណុចទី ១៥ ។

### ២.១.១ ការព្រមព្រៀង

ការព្រមព្រៀង គឺជាឆន្ទៈរបស់ភាគីនីមួយៗក្នុងការបង្កើតកិច្ចសន្យា ។ ពាក្យថាការព្រមព្រៀងសំដៅលើការសម្តែងនូវបំណងរបស់ភាគីមកខាងក្រៅ ។ ការព្រមព្រៀងត្រូវតែធ្វើដោយពិតប្រាកដ និង ដោយសេរី ហើយជាការព្រមព្រៀងដែលពុំមានអធម៌ដែលជាវិការៈប៉ះពាល់ដល់ការព្រមព្រៀង ។ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ត្រូវចាត់ទុកការបង្ហាញឆន្ទៈមានវិការៈក្នុងករណីដូចខាងក្រោមនេះ៖

- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។
- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬការគម្រាមកំហែង ឬការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។
- ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពីឆ្លៀតឱកាស ដោយមានគោលបំណងកេងចំណេញហួសហេតុ ។

សេចក្តីព្រៀងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម មាត្រា ៦ បានបញ្ញត្តិថា កិច្ចសន្យាពាណិជ្ជកម្ម ត្រូវបានបង្កើតឡើងនៅពេលដែលសំណើ និង ស្ទីការត្រូវគ្នា ។ រីឯមាត្រា ៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៧ បញ្ញត្តិថា កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្ទីការត្រូវគ្នា ។ សំណើ មានន័យថាគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណាងគតិយុត្តិក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ[២៧] ។ ចំណែកឯពាក្យថាស្ទីការវិញមានន័យថា ជាការបង្ហាញឆន្ទៈដែលទទួលសំណើយល់ព្រមចំពោះសំណើនោះ[២៨] ។

វិលមកមើលអំពីក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងជាក្រុមហ៊ុនដែលធ្វើពាណិជ្ជកិច្ចពាក់ព័ន្ធនឹងការផ្តល់សេវាកម្មប្រឹក្សាផ្នែកធានធានមនុស្ស ដូច្នេះនេះគឺជាប្រភេទមួយនៃពាណិជ្ជកិច្ចដែលទាក់ទងនឹងកិច្ចសន្យាម៉ៅការ ។ មាត្រា ១៥៨ នៃសេចក្តីព្រៀងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម បានបញ្ញត្តិថា កិច្ចសន្យាម៉ៅការសំដៅដល់កិច្ចសន្យាដែលក្នុងនោះអ្នកម៉ៅការជាពាណិជ្ជករចង់ភ្ជាប់កាតព្វកិច្ចជាមួយម្ចាស់ការជាពាណិជ្ជករ ឬមិនមែនជាពាណិជ្ជករក្នុងគោលបំណងអនុវត្តការងារដោយទទួលការទូទាត់ថ្លៃពីម្ចាស់ការ ។ ការអនុវត្តន៍ការងារខាងលើនេះអាចជាកិច្ចសន្យា ឬសេវា

[២៧] មាត្រា ៣៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៧ ។

[២៨] មាត្រា ៣៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៧ ។

ហើយសេវា សំដៅដល់ភារកិច្ចដែលត្រូវបំពេញជាប្រចាំដោយអ្នកម៉ៅការចំពោះម្ចាស់ការ រួមមានដូចជា ការប្រឹក្សា ការថែទាំ ឬការជួសជុល[២៩] ។

នៅក្នុងការបង្កើកិច្ចសន្យារវាងក្រុមហ៊ុនប៊្លូអេចអ ខនសាល់ធីង និង អថិជនក៏ត្រូវមានការព្រមព្រៀងនឹងគ្នាផងដែរ ហើយសម្រាប់ទម្រង់នៃការព្រមព្រៀងនេះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ និង ត្រូវមានការចុះហត្ថលេខារបស់ភាគីទាំងសងខាង ។ ជាក់ស្ដែងនៅក្នុងបុព្វកថានៃស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពី សេវាកម្មរើសបុគ្គលិករបស់ក្រុមហ៊ុននេះបានបញ្ញាតថា "លក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះធ្វើឡើងរវាង **ក្រុមហ៊ុនប៊្លូអេចអ ខនសាល់ធីង** ដែលហៅថាភាគី **"ប្លូអេចអ ខនសាល់ធីង"** ជាមួយ **"ក្រុមហ៊ុន"** ដែលហៅថាភាគី **"អតិថិជន"** ហើយសន្មត់ថា បានយល់ព្រមពីភាគីអតិថិជនតាមរយៈការចុះហត្ថលេខាយល់ស្របទៅលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ។ លក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះមានសុពលភាពដរាបណាមានការកែប្រែ ឬមានការផ្តល់នូវការសរសេរជាលាយលក្ខណ៍អក្សរត្រឹមត្រូវ និង យល់ព្រមដោយភាគីទាំងសងខាងទៅលើលក្ខខណ្ឌដែលត្រូវផ្លាស់ប្តូរ ។ បន្ថែមពីលើនេះទៀត ចំណុចទី ១០ នៃស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មជ្រើសរើសបុគ្គលិកបានបញ្ញាត្តិយ៉ាងច្បាស់ថា "ខ្ញុំ តំណាងឱ្យក្រុមហ៊ុននៃភាគីអតិថិជនរបស់ក្រុមហ៊ុនបានយល់ច្បាស់ និង ព្រមព្រៀងទៅតាមលក្ខណនៅក្នុងកិច្ចសន្យានេះ ហើយព្រមធ្វើការសហការជាមួយភាគីប៊្លូអេចអ ខនសាល់ធីងដើម្បីស្វែងរកបេក្ខជនដែលសាកសមទៅតាមការពិភាក្សាគ្នា ។ ខ្ញុំក៏ត្រូវបានទទួលស្គាល់ថាជាតំណាងឱ្យក្រុមហ៊ុននៃភាគីអតិថិជន ខ្ញុំមានសិទ្ធិក្នុងការចុះហត្ថលេខាក្នុងនាមជាក្រុមហ៊ុនដែលបានបញ្ជាក់ខាងលើ" ។

ម្យ៉ាងវិញទៀត ក្នុងបុព្វកថានៃលក្ខខណ្ឌនៃកិច្ចព្រមព្រៀងសេវាកម្មប្រឹក្សាផ្នែកច្បាប់ការងារក៏បានចែងដែលថា លក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះមានសុពលភាពលុះត្រាតែមានការចុះហត្ថ-លេខាយល់ព្រមពីភាគីទាំងសងខាងផងដែរ ។

មាត្រា ៧ នៃសេចក្តីព្រៀងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម បានបើកទូលាយសម្រាប់ទម្រង់នៃការបង្កើតកិច្ចសន្យាពាណិជ្ជកម្មគឺអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក៏បាន មាត្រានេះដ៏ដែលក៏បានបញ្ញាត្តិដែរថា ចំពោះកិច្ចសន្យាផ្ទាល់មាត់ត្រូវបានកំណត់មិនលើសពី ២០០០,០០០ (ពីរលាន) រៀល ។ ដោយឡែកកិច្ចសន្យានោះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ប្រសិនបើះ

[២៩] មាត្រា១៥៩ នៃសេចក្តីព្រៀងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ។

- កិច្ចសន្យានោះជាកិច្ចសន្យាដែលត្រូវចុះហត្ថលេខាដោយភាគី ឬដែលស្ថិតនៅក្នុងការផ្លាស់ប្តូរលិខិតស្នាម
- កិច្ចសន្យានោះធ្វើឡើងដោយមធ្យោបាយទូរគមនាគមន៍ តាមប្រព័ន្ធអេឡិចត្រូនិច ដែលមានត្រាបញ្ជាក់កំណត់អំពីកិច្ចសន្យាហើយទទួលស្គាល់ដោយច្បាប់ ឬ
- កិច្ចសន្យានោះជាពាក្យទាមទារ ឬពាក្យឆ្លើយតបរបស់ភាគីលើកិច្ចសន្យាដែលមានស្រាប់ ។

## ២.១.២ សមត្ថភាពនៃភាគី

ដើម្បីឱ្យកិច្ចសន្យាមានសុពលភាព ការសម្តែងឆន្ទៈត្រូវតែកើតពីជនដែលមានសមត្ថភាពក្នុងការធ្វើកិច្ចសន្យា ។ សមត្ថភាពនៃភាគី សំដៅដល់សមត្ថភាពក្នុងការចុះកិច្ចសន្យាពាណិជ្ជកម្មរវាងអ្នកផ្តល់សេវាកម្ម និង អ្នកទទួលសេវាកម្ម ។ ជាគោលការណ៍ សមត្ថភាពរបស់ភាគីក្នុងការបង្កើតកិច្ចសន្យាត្រូវអនុលោមទៅតាមនីតិពាណិជ្ជកម្ម និង ក្រមរដ្ឋប្បវេណី ។ បើតាមក្រមរដ្ឋប្បវេណី រូបវន្តបុគ្គលអាចបង្កើតកិច្ចសន្យាបាននៅពេលដែលរូបវន្តបុគ្គលនោះមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ឬជនដែលទទួលបានអត្តាធិនភាព ។ ដោយឡែកចំពោះនីតិបុគ្គលវិញ កិច្ចសន្យាត្រូវបានបង្កើតឡើងដោយអ្នកតំណាងរបស់ក្រុមហ៊ុននោះជាមួយនឹងអតិថិជន ។

កិច្ចសន្យាដែលក្រុមហ៊ុនប៊្លូអេចអ ខនសាល់ធីងធ្វើឡើងជាមួយអតិថិជនមានពីរគឺកិច្ចសន្យាជ្រើសរើសបុគ្គលិក និង កិច្ចសន្យាប្រឹក្សាច្បាប់ការងារ ហើយកិច្ចសន្យាទាំងនេះត្រូវចុះហត្ថលេខាដោយអ្នកតំណាងក្រុមហ៊ុន ។

## ២.១.៣ កម្មវត្ថុនៃកិច្ចសន្យា

កិច្ចសន្យាមួយមានសុពលភាព លុះត្រាតែកិច្ចសន្យានោះមិនផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់ធារណៈ និង ទំនៀមទម្លាប់ល្អ[៣០] ។ម្យ៉ាងទៀតក្រឹត្យ-ច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា មាត្រា ៣ កថាខណ្ឌទី៣ បានចែងថា កិច្ចសន្យាទាំងឡាយនឹងយកជាការបានលុះត្រាណាតែកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យានោះមានកម្មវត្ថុមួយជាក់លាក់ដែលអាចធ្វើកើត និង ស្របច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទម្លាប់ដ៏ល្អប្រពៃ ។

[៣០] មាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៧ ។

កម្មវត្ថុជាក់លាក់ មានន័យថាភាគីកិច្ចសន្យាយល់ច្បាស់ពីអ្វីដែលខ្លួនសន្យា ។ កម្មវត្ថុជាក់លាក់ក៏មានន័យដែរថាជាកម្មវត្ថុត្រូវតែមាននៅពេលបច្ចុប្បន្ន ។ ហេតុនេះប្រសិនបើកម្មជាវត្ថុមិនមាននៅពេលចុះកិច្ចសន្យាដោយសារវត្ថុនោះបាត់បង់ កិច្ចសន្យានឹងពុំមានសុពលភាពឡើយ ។

កម្មវត្ថុនៃកិច្ចសន្យា ដែលមិនអាចធ្វើកើតដោយមនុស្សទូទៅនឹងនាំឱ្យកិច្ចសន្យាមោឃៈ ។ កម្មវត្ថុមិនអាចធ្វើកើតអាស្រ័យដោយបញ្ហាពីរយ៉ាងគឺ ទី១ ភាពមិនអាចធ្វើទៅកើតដោយសារតែអំពើនោះតែម្តង ដូចជាទិញលក់ព្រះអាទិត្យជាដើម និង ទី២ ភាពមិនអាចធ្វើកើតដោយសារតែច្បាប់ ឧទាហរណ៍ ការលក់វត្ថុដែលច្បាប់ហាមឃាត់ជាដើម ។ ដើម្បីកំណត់ថាកិច្ចសន្យាត្រូវចាត់ទុកជាមោឃៈដោយសារតែភាពមិនអាចកើតឡើងគេត្រូវពិនិត្យមើលថា តើភាពមិនអាចធ្វើទៅកើតនោះមានលក្ខណៈដាច់ខាត ឬមិនអាចដាច់ខាត បើមានលក្ខណៈដាច់ខាតនោះកិច្ចសន្យាត្រូវទុកជាមោឃៈ ផ្ទុយទៅវិញបើមានលក្ខណៈមិនដាច់ខាតនោះកិច្ចសន្យានៅតែមានសុពលភាពដដែល ។

ដើម្បីឱ្យកម្មវត្ថុស្របច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទម្លាប់ដ៏ល្អប្រពៃ កម្មវត្ថុនៃកិច្ចសន្យាស្ថិតនៅក្នុងពាណិជ្ជកម្ម លុះត្រាតែកម្មវត្ថុនៃកិច្ចសន្យាគឺមិនត្រូវបានហាមឃាត់ដោយច្បាប់ជាដាច់ខាតដោយហេតុថា នៅក្នុងច្បាប់របស់យើងបានធ្វើការហាមឃាត់វត្ថុមួយចំនួន គឺមិនអាចធ្វើការលក់ដូបានឡើយដូចជា ខ្លួនមនុស្ស ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង ទង្វើផ្ទាល់ខ្លួនរបស់មនុស្សដែលសន្យាថានឹងប្រព្រឹត្តបទល្មើស ។

យោងតាមលក្ខន្តិកៈរបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣ ប្រការ ២ បានចែងអំពីកម្មវត្ថុអាជីវកម្មផ្សេងៗរបស់ក្រុមហ៊ុនដូចបានសរសេររៀបរាប់នៅក្នុងជំពូក ទី ១ ខាងលើ ។ ប៉ុន្តែនៅក្នុងសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុននាពេលបច្ចុប្បន្ន គឺក្រុមហ៊ុនផ្តល់សេវាកម្មពិគ្រោះយោបល់ផ្នែកធនធានមនុស្ស ហើយក្នុងសេវាកម្មនេះមានសេវាកម្មដូចជា សេវាកម្មជ្រើសរើសបុគ្គលិក និង សេវាកម្មប្រឹក្សាច្បាប់ការងារ ។

### ក. កិច្ចសន្យាសេវាកម្មជ្រើសរើសបុគ្គលិក

កិច្ចសន្យាសេវាកម្មជ្រើសរើសបុគ្គលិក គឺជាកិច្ចសន្យាដែលមានគោលបំណងផ្តល់សេវាជូនអតិថិជននូវបេក្ខជនប្រកបដោយសមត្ថភាព និង ទេពកោសល្យ ។ ហើយកិច្ចសន្យានេះត្រូវធ្វើឡើងរវាងភាគីក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ជាមួយភាគីក្រុមហ៊ុនដែលជាអតិថិជន ។ ឧទាហរណ៍ ក្រុមហ៊ុនទេសចរណ៍មួយឈ្មោះ "ក" ត្រូវការជ្រើសរើសបុគ្គលិកផ្នែកគណនេយ្យករមួយរូប ហើយក្រុម

ហ៊ុននេះបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ព្រមព្រៀងប្រើប្រាស់នូវសេវាកម្ម ជ្រើសរើសបុគ្គលិករបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ។

### ខ. កិច្ចសន្យាសេវាកម្មប្រឹក្សាច្បាប់ការងារ

ជាប្រភេទនៃកិច្ចសន្យាដែលក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងផ្តល់ជូនអតិថិជននូវសេវាកម្ម ពាក់ព័ន្ធនឹងការប្រឹក្សាច្បាប់ការងារដែលរួមមាន[៣១]៖

- ការស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស
- ការស្នើសុំសៀវភៅការងារសម្រាប់បុគ្គលិកជាជនជាតិខ្មែរ និង ជនបរទេស
- ប្រកាសជូនដំណឹងបើក ឬបិទសហគ្រាស គ្រឹះស្ថាន
- ការចុះបញ្ជីបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន
- សៀវភៅបញ្ជីប្រចាំសហគ្រាស គ្រឹះស្ថាន
- សៀវភៅបើកប្រាក់ និង បញ្ជីបើកប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច
- ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក
- ប្រកាសជូនដំណឹងស្តីពីចលនាបុគ្គលិក
- ការសម្របសម្រួលដំណើរការពិនិត្យសុខភាពជាមួយក្រសួងការងារ
- ការស្នើសុំការអនុញ្ញាតពីក្រសួងការងារចំពោះការធ្វើការបន្ថែមម៉ោង
- ការចុះបញ្ជីរបបសន្តិសុខសង្គម (បសស)

### ២.១.៤ តម្លៃតបស្នង

ម្ចាស់ការត្រូវបង់ថ្លៃឈ្នួលតាមការព្រមព្រៀង និង តាមការកំណត់ដូចមានចែងក្នុងកិច្ចសន្យាម៉ៅការទៅឱ្យអ្នកម៉ៅការ ហើយប្រសិនបើមិនមានខចែងអំពីកាលកំណត់បង់ថ្លៃឈ្នួល នៅក្នុងកិច្ចសន្យាម៉ៅការទេ នោះម្ចាស់ការត្រូវបង់ថ្លៃឈ្នួលបន្ទាប់ពីការងារត្រូវបានអនុវត្តចប់សព្វគ្រប់[៣២] ។ ក្នុងចំណុចនេះក្រុមហ៊ុនដែលជាអតិថិជន ត្រូវបង់ថ្លៃឈ្នួលជូនក្រុមហ៊ុនដែលជាអ្នកផ្តល់សេវាកម្ម ។ ភាគីអតិថិជនមិនចំណាយលើតម្លៃជំនាញការណ៍ដល់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង នោះទេ ប្រសិនបើមុខតំណែងដែលភាគីអតិថិជនធ្វើការជ្រើសរើសមិនបានបំពេញដោយបេក្ខជនពី

[៣១] យោងតាមឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មប្រឹក្សាច្បាប់ការងារ ។
[៣២] មាត្រា ១៧២ នៃសេចក្តីព្រៀងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ។

ភាគីប្លូអេចអ ខនសាល់ធីង ហើយក៏មិនមានការតម្រូវឱ្យចំណាយពីភាគីអតិថិជនដោយគ្រាន់តែការសាកសួរពត៌មាន ឬគ្រាន់តែធ្វើការចុះហត្ថលេខាទៅលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះ[៣៣] ។

ម្យ៉ាងវិញទៀតនៅចំណុចទី១ កថាខណ្ឌទី២ ៣ និង ៤ នៃស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មជ្រើសរើសបុគ្គលិករបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងបានចែងថា តម្លៃជំនាញការណ៍ត្រូវបានគណនាដោយគិតទៅលើប្រាក់បៀវត្សរ៍ដោយមិនទាន់កាត់ពន្ធរបស់បេក្ខជនបន្ទាប់ពីការសាកល្បងការងារ លើកលែងតែភាគីទាំងពីរមានការព្រមព្រៀងគ្នាទៅលើប្រការណាមួយដោយឡែក ។ ប្រាក់បៀវត្សរ៍ដោយមិនទាន់កាត់ពន្ធរបស់បេក្ខជន គឺមិនរាប់បញ្ចូលប្រាក់លើកទឹកចិត្ត និង ប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់ជូលបេក្ខជនឡើយ លើកលែងតែភាគីទាំងពីរមានការព្រមព្រៀងគ្នាទៅលើប្រកាណាមួយផ្សេងពីនេះ ។ សូមបញ្ជាក់ដែលថា តម្លៃជំនាញការណ៍នឹងត្រូវគិតថ្លៃហើយភាគីអតិថិជនមានកាតព្វកិច្ចទូទាត់សងនៅពេលដែលបេក្ខជនចាប់ផ្តើមការងារ មិនមែននៅពេលដែលបេក្ខជនចប់ការសាកល្បងការងារនោះទេ ។

## ២.២ អានុភាពនៃកិច្ចសន្យា

នៅពេលដែលភាគីបានបង្កើតកិច្ចសន្យា ដែលស្របតាមលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យានោះនាំឱ្យកិច្ចសន្យានោះបង្កើតនូវចំណងគតិយុត្តិចំពោះភាគី ពោលគឺភាគីត្រូវទទួលបាននូវសិទ្ធិ និង ការតព្វកិច្ចដែលកើតចេញពីកិច្ចសន្យានោះ ។ ការអនុវត្តន៍សិទ្ធិ និង កាតព្វកិច្ចទាំងនេះត្រូវស្របតាមគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។ ក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ ២០០៧ មាត្រា ៥ (គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់) បានចែងដែរថា ការប្រើប្រាស់សិទ្ធិ និង ការអនុវត្តន៍ករណីយកិច្ច ត្រូវធ្វើឡើងដោយសុចរិតផ្អែកតាមភាពស្មោះត្រង់ ។ មាត្រា ៥ នេះចង់បញ្ជាក់ថានៅពេលបង្កើតកិច្ចសន្យា ក៏ដូចជានៅពេលប្រើប្រាស់សិទ្ធិ និង អនុវត្តកាតព្វកិច្ចតាមទំនាក់ទំនងសិទ្ធិ និង កាតព្វកិច្ចដែលត្រូវបានបង្កើតឡើងនោះ ភាគីត្រូវធ្វើសកម្មភាពដោយមានភាពស្មោះត្រង់ ដោយផ្អែកលើទំនាក់ទំនងទុកចិត្តគ្នាទៅវិញទៅមកដើម្បីកុំឱ្យមានការក្បត់គ្នា ទើបទំនាក់ទំនងជួញដូរផ្អែកឯកជនមានភាពរលូន ។ ជាពិសេសក្នុងករណីដែលហេតុការណ៍ដែលភាគីមិនបានព្យាករណ៍ទុកជាមុនកើតឡើង នោះភាគីសងខាងត្រូវដោះស្រាយដោយផ្អែកតាមភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក ។

[៣៣] ចំណុច ១ កថាខណ្ឌទី១ នៃស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មរើសបុគ្គលិក ។

កិច្ចសន្យាពាណិជ្ជកម្មដែលធ្វើឡើងដោយភាគីប្លូអេចអ ខនសាល់ធីងជាមួយនឹងភាគីអតិថិជននឹងធ្វើឱ្យភាគីទាំងពីរទទួលបានទាំងសិទ្ធិ និង ការតព្វកិច្ចដែលសិទ្ធិ និង ការតព្វកិច្ចទាំងនោះកើតឡើងតាមរយៈកិច្ចសន្យាជ្រើសរើសបុគ្គលិក និង កិច្ចសន្យាប្រឹក្សាច្បាប់ការងារ ។

### ២.២.១ សិទ្ធិរបស់ភាគី

សិទ្ធិរបស់ភាគីទីនេះ សំដៅលើអ្វីដែលភាគីអាចទាមទារឱ្យភាគីម្ខាងទៀតអនុវត្តនូវការតព្វកិច្ច ឬទទួលបាននូវតារលិកអ្វីមួយដែលមានចែងក្នុងកិច្ចសន្យា ។ ក្នុងចំណុចនេះសូមលើកយកមកបង្ហាញជូននូវសិទ្ធិរបស់ភាគីប្លូអេចអ ខនសាល់ធីង និង ភាគីអតិថិជនដែលកើតឡើងតាមរយៈកិច្ចសន្យាជ្រើសរើសបុគ្គលិក និង កិច្ចសន្យាប្រឹក្សាច្បាប់ការងារ ។

#### ក. សិទ្ធិរបស់ភាគីទទួលសេវាកម្ម

បន្ទាប់ពីបានចុះកិច្ចសន្យាព្រមព្រៀងប្រើប្រាស់នូវសេវាកម្មរួចហើយ ភាគីទទួលបានសិទ្ធិដូចមានចែងក្នុងកិច្ចសន្យា ហើយសិទ្ធិដែលអតិថិជនទទួលបានពីការធ្វើពាណិជ្ជកិច្ចជាមួយក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងត្រូវកើតឡើងតាមរយៈកិច្ចសន្យាដូចខាងក្រោម៖

#### ក.១ សិទ្ធិទទួលបានតាមរយៈកិច្ចសន្យាជ្រើសរើសបុគ្គលិក

ភាគីអតិថិជននឹងទទួលបានបេក្ខជនប្រកបដោយសមត្ថភាព និង ទេពកោសល្យ ហើយនៅពេលដែលភាគីអតិថិជនចង់ធ្វើការផ្សព្វផ្សាយមុខតំណែងតាមរយៈភាគីប្លូអេចអ ខនសាល់ធីង នោះភាគីប្លូអេចអ ខនសាល់នឹងជួយធ្វើការរៀបចំនូវការផ្សព្វផ្សាយការងារនោះ ហើយនៅពេលដែលរៀបចំរួចរាល់ ភាគីប្លូអេចអ ខនសាល់ធីងនឹងដាក់ជូនទៅភាគីអតិថិជនដើម្បីពិនិត្យ និង យល់ស្រប ។ លើសពីនេះទៅទៀត ភាគីអតិថជនក៏មានសិទ្ធិដឹងអំពីថ្លៃផ្សេងៗដែលទាក់ទងនឹងការផ្សព្វផ្សាយនេះ[៣៤] ។

ជាគោលការណ៍ក្នុងរយៈពេលមួយសប្តាហ៍ ភាគីអតិថិជនអាចនឹងទទួលនូវបេក្ខជនដែលបានជ្រើសរើសចុងក្រោយពីភាគប្លូអេចអ ខនសាល់ធីង ។ រយៈពេលមួយសប្តាហ៍នេះត្រូវបានរាប់បន្ទាប់ពីភាគីប្លូអេចអ ខនសាល់ធីងទទួលបានពត៌មានចាំបាច់ទាក់ទងនឹងមុខតំណែងដែលអតិថិជនចង់ស្វែងរក ។ សូមបញ្ជាក់ដែរថា ភាគីអតិថិជនក៏នូវតែមានសិទ្ធិស្វែងរកបេក្ខជនដោយខ្លួនឯង

[៣៤] ចំណុចទី ៤ នៃស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មរើសបុគ្គលិក ។

បានផងដែរ បើទោះបីជាភាគីនេះបានព្រមព្រៀងប្រើប្រាស់នូវសេវាកម្មជ្រើសរើសបុគ្គលិកនេះក៏ដោយ[៣៥] ។

ការសម្រេចជួលបេក្ខជនណាមួយធ្វើជាបុគ្គលិករបស់ភាគីអតិថិជន គឺភាគីអតិថិជនជាអ្នកមានសិទ្ធិសម្រេច ។ បេក្ខជនត្រូវបានឆ្លងកាត់ការសំភាសន៍ជាមួយភាគីប្លូអេចអ ខនសាល់ធីងនៅជុំទី១ បន្ទាប់មកបើបេក្ខជនមានសមត្ថភាព និង ទេពកោសល្យត្រូវនឹងអ្វីដែលភាគីអតិថិជនចង់បាន បេក្ខជននោះនឹងត្រូវបញ្ជូនទៅភាគីអតិថិជនធ្វើការពិនិត្យប្រវត្តិរូប និង សំភាសន៍ ហើយបន្ទាប់មកភាគីអតិថិជនអាចសម្រេចថាទទួលយកបេក្ខជននោះមកធ្វើការក្នុងក្រុមហ៊ុនរបស់ខ្លួន ឬមិនទទួលយក ។

### ក.២ សិទ្ធិទទួលបានតាមរយៈកិច្ចសន្យាប្រឹក្សាច្បាប់ការងារ

នៅក្នុងកិច្ចសន្យានេះមិនមានចែងច្បាស់អំពីសិទ្ធិរបស់ភាគីអតិថិជននោះទេ ប៉ុន្តែទោះបីជាយ៉ាងនេះក្តីក៏តាមរយៈកិច្ចសន្យានេះ ភាគីអតិថិជននឹងទទួលបាននូវសេវាកម្មដែលបានព្រមព្រៀងគ្នាជាមួយភាគីប្លូអេចអ ខនសាល់ធីងប្រកបដោយគុណភាព និង តាមកាលកំណត់ ។ ដោយសារសេវាកម្មនេះពាក់ព័ន្ធច្រើនជាមួយការបំពេញបែបបទនូវឯកសារផ្សេងៗ ដែលត្រូវមានការអនុញ្ញាតពីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យក្រុមហ៊ុនស្របនឹងច្បាប់ការងាររបស់កម្ពុជាដូច្នេះសិទ្ធិដែលចម្បងនោះ គឺភាគីអតិថិទទួលបានឯកសារពេញលេញពីដំណើរការទាំងនេះ ។ ក្នុងករណីភាគីប្លូអេចអ ខនសាល់ធីងមិនបានបំពេញការងារនេះតាមកាលកំណត់ទេនោះ ភាគីអតិថិជនមានសិទ្ធិទាមទារសំណងបាន ។ ម្យ៉ាងវិញទៀតភាគីអតិថិជនក៏មានសិទ្ធិផ្តាច់កិច្ចសន្យានេះផងដែរ (សិទ្ធិនេះធ្វើទៅបានលុះត្រាតែភាគីទាំងសងខាងមិនអនុវត្តកិច្ចសន្យា) ។

### ខ. សិទ្ធិរបស់ភាគីផ្តល់សេវាកម្ម

ភាគីប្លូអេចអ ខនសាល់ធីងទទួលបានសិទ្ធិតាមរយៈកិច្ចសន្យាជ្រើសរើសបុគ្គលិក និង កិច្ចសន្យាប្រឹក្សាច្បាប់ការងារ ដែលខ្លួនបានព្រមព្រៀងគ្នាជាមួយនឹងក្រុមហ៊ុនអតិថិជន ។ សិទ្ធិទាំងនោះមានដូចខាងក្រោម៖

[៣៥] ចំណុចទី ៥ នៃស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មរើសបុគ្គលិក ។

### ខ.១ សិទ្ធិទទួលបានតាមរយៈកិច្ចសន្យាជ្រើសរើសបុគ្គលិក

ដើម្បីឱ្យភាគីប្លូអេចអ ខនសាល់ធីងផ្តល់ជូនបេក្ខជនដែលមានសមត្ថភាពឱ្យភាគីអតិថិជនបាន ភាគីប្លូអេចអ ខន់សាល់ធីងមានសិទ្ធិទទួលយកពត៌មានចំពោះមុខតំណែងដែលភាគីអតិថិជនជ្រើសរើស ហើយពត៌មានទាំងនោះមានដូចជា ឈ្មោះមុខតំណែង ការពិពណ៌នាពីការងារ ប្រាក់បៀវត្សរ៍នៃមុខតំណែង និង ថ្ងៃស្នើសុំក្នុងការចាប់ផ្តើមការងារ ។ សិទ្ធិសំខាន់មួយទៀតនោះគឺសិទ្ធិក្នុងការទទួលបានតម្លៃតបពីសេវាកម្មដែលខ្លួនផ្តល់ឱ្យអតិថិជន ។

### ខ.២ សិទ្ធិទទួលបានតាមរយៈកិច្ចសន្យាប្រឹក្សាច្បាប់ការងារ

សិទ្ធិដែលភាគីប្លូអេចអ ខនសាល់ធីងទទួលបានពីកិច្ចសន្យាប្រឹក្សាច្បាប់ការងារមានដូចជា សិទ្ធិទទួលថ្លៃសេវាទៅតាមការព្រមព្រៀង សិទ្ធិទទួលបានឯកសារគ្រប់គ្រាន់សម្រាប់ដំណើការរត់ការជាមួយក្រសួង សិទ្ធិផ្តាច់កិច្ចសន្យា (សិទ្ធិនេះធ្វើទៅបានលុះត្រាតែភាគីទាំងសងខាងមិនទាន់បានអនុវត្តកិច្ចសន្យា) ។ ដូចក្នុងកិច្ចព្រមព្រៀងសេវាកម្មប្រឹក្សាច្បាប់ការងារ ត្រង់ចំណុចទី ១ បានចែងថា ប្រសិនបើអតិថិជនខកខានមិនបានផ្តល់ជូនឯកសារតម្រូវទាន់ពេលវេលាកំណត់ ដែលបានព្រមព្រៀងគ្នានោះទេ ភាគីប្លូអេចអ ខនសាល់ធីងមានសិទ្ធិពិន័យទៅលើតម្លៃបន្ថែមទៀត ហើយភាគីប្លូអេចអ ខនសាល់ធីងមិនទទួលខុសត្រូវចំពោះការយឺតយ៉ាវរបស់អតិថិជននោះទេ ។

### ២.២.២ ភាតព្វកិច្ចរបស់ភាគី

ផ្អែកតាមកិច្ចសន្យាជ្រើសរើសបុគ្គលិក និង កិច្ចសន្យាប្រឹក្សាច្បាប់ការងារ ភាគីដែលបានព្រមព្រៀងគ្នាចុះហត្ថលេខាលើកិច្ចសន្យានេះ ពោលគឺភាគីប្លូអេចអ ខនសាល់ធីងជាមួយនឹងអតិថិជនត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងខចែងក្នុងកិច្ចសន្យាទាំងពីរនេះ ។ ម្យ៉ាងវិញទៀត មាត្រា ១៦៧ នៃសេចក្តីព្រៀងច្បាប់ស្តីកិច្ចសន្យាពាណិជ្ជកម្មក៏បានបញ្ញាតថា ភាគីនៃកិច្ចសន្យាម៉ៅការ ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របតាមកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

ដូច្នេះកាតព្វកិច្ចរបស់ភាគីនៅទីនេះ សំដៅដល់កិច្ចការដែលភាគីប្លូអេចអ ខនសាល់ធីង និង ភាគីអតិថិជនត្រូវបំពេញ ។

### ក. ភាតព្វកិច្ចរបស់ភាគីទទួលសេវាកម្ម

អតិថិជនដែលបានព្រមព្រៀងក្នុងការចុះកិច្ចសន្យា ប្រើប្រាស់នូវសេវាកម្មរបស់ក្រុមហ៊ុន ប្លូអេចអ ខនសាល់ធីង ត្រូវមានកាតព្វកិច្ចដូចមានក្នុងខចែងនៃកិច្ចសន្យា ។ កាតព្វកិច្ចទាំងនោះនឹង ត្រូវកើតឡើងតាមរយៈការចុះកិច្ចសន្យាជ្រើសរើសបុគ្គលិក និង កិច្ចសន្យាប្រឹក្សាច្បាប់ការងារ ។

#### ក.១ កាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាជ្រើសរើសបុគ្គលិក

នៅពេលដែលកិច្ចសន្យាការងារ ឬលិខិតផ្តល់ជូនការងារ ឬទម្រង់នៃកិច្ចសន្យាផ្សេងៗ ដែលផ្តល់ជូនបេក្ខជន ភាគីអតិថិជនត្រូវយល់ព្រមផ្តល់ដំណឹងដល់ភាគីប្លូអេចអ ខនសាល់ធីងភ្លាម តាមរយៈសារ ឬសំបុត្រដោយបញ្ជាក់ពីឈ្មោះបេក្ខជនដែលត្រូវជួល មុខតំណែង ប្រាក់បៀវត្សរ៍ មិនទាន់កាត់ ពន្ធដែលមានចែងក្នុងកិច្ចសន្យា និង ថ្ងៃចាប់ផ្តើមធ្វើការ ។ វិក័យបត្រនឹងត្រូវធ្វើជូនទៅ ភាគីអតិថិជននៅពេលដែល បេក្ខជនបានអះអាងដោយបានដាក់លិខិតលាឈប់ពីការងារបច្ចុប្បន្ន និង បានចុះហត្ថលេខាលើកិច្ចសន្យាការងារ ឬលិខិតផ្តល់ជូនការងារពីភាគីអតិថិជន ។ ការទូទាត់ សងទៅលើតម្លៃជំនាញការណ៍ និង ការចំណាយទៅលើថ្លៃផ្សព្វផ្សាយ ឬថ្លៃផ្សេងៗទៀតជា កាតព្វកិច្ចរបស់ភាគីអតិថិជនដែលត្រូវទូទាត់ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃកាលបរិច្ឆេទលើ វិក័យបត្រ[៣៦] ។

ម្យ៉ាញវិញទៀត ភាគីអតិថិជនត្រូវផ្តល់ពត៌មានជូនភាគីប្លូអេចអ ខនសាល់ធីងនៅពេល ដែលខ្លួនត្រូវការជ្រើសរើសបុគ្គលិក ។ ពត៌មានទាំងនោះមានដូចជា ឈ្មោះមុខតំណែង ការ ពិពណ៌នាពីការងារ (ទំនួលខុសត្រូវការងារ និង លក្ខខណ្ឌតម្រូវ) ប្រាក់បៀវត្សរ៍នៃមុខតំណែង ថ្ងៃ ស្នើសុំក្នុងការចាប់ផ្តើមការងារ[៣៧] ។ លើសពីនេះទៅទៀត ភាគីអតិថិជននឹងត្រូវទទួលខុសត្រូវលើ ការងារ និង លិខិតអនុញ្ញាតផ្សេងៗសម្រាប់ការរៀបចំលើការត្រួតពិនិត្យសុខភាពដោយបានតម្រូវ ដោយការអនុវត្តន៍តាមច្បាប់ ។ ភាគីអតិថិជនត្រូវរក្សាការសម្ងាត់ពីពត៌មានរបស់បេក្ខជនដែលត្រូវ បង្ហាញជូនភាគីអតិថិជនពីភាគីប្លូអេចអ ខនសាល់ធីង ហើយមិនត្រូវប្រកាសឱ្យភាគីទី ៣ ផ្សេង ទៀតដឹងពីលក្ខណ្ឌទាំងអស់នៅក្នុងផ្នែកណាមួយនៃកិច្ចសន្យានេះនោះទេ ។

[៣៦] ចំណុចទី ២ នៃស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មរើសបុគ្គលិក ។

[៣៧] ចំណុចទី ៣ នៃស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មរើសបុគ្គលិក ។

### ក.២ កាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាប្រឹក្សាច្បាប់ការងារ

អតិថិជនត្រូវតែបញ្ជាក់កាលបរិច្ឆេទកំណត់ណាមួយ សម្រាប់ផ្តល់ឯកសារដែលក្រុមហ៊ុនទាមទារទាំងអស់ និង ត្រូវបំពេញទម្រង់បែបបទឯកសារទាំងអស់នោះជូនភាគីប្លូអេចអ ខនសាល់ធីង[៣៨] ។

ភាគីអតិថិជនមានកាតព្វកិច្ចចំណាយ ១០០ (មួយរយ) ភាគរយ ទៅលើសេវាកម្មដែលខ្លួនប្រើប្រាស់ ហើយការចំណាយនេះត្រូវធ្វើឡើងក្នុងរយៈ ៧ (ប្រាំពីរ) ថ្ងៃប្រតិទិន គិតចាប់ថ្ងៃដែលភាគីអតិថិជនបានទទួលវិក័យបត្រ[៣៩] ។

### ខ. ភាតព្វកិច្ចរបស់ភាគីផ្តល់សេវាកម្ម

ជាគោលការណ៍ នៅក្នុងកិច្ចសន្យាមួយត្រូវមានចែងអំពីកាតព្វកិច្ចរបស់ភាគី តួយ៉ាងនៅក្នុងកិច្ចសន្យាជ្រើសរើសបុគ្គលិក និង ប្រឹក្សាច្បាប់ការងារដែលធ្វើឡើងដោយក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងជាមួយអតិថិជនរបស់ខ្លួនក៏បានចែងផងដែរអំពីកាតព្វកិច្ចរបស់ភាគីប្លូអេចអ ខនសាល់ធីង ។ កាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាទាំងពីរនេះមានដូចខាងក្រោម៖

### ខ.១ កាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាជ្រើសរើសបុគ្គលិក

ភាគីប្លូអេចអ ខនសាល់ធីងត្រូវធ្វើការស្វែងរកបេក្ខជនជូនភាគីអតិថិជន ទៅតាមលក្ខខណ្ឌនៃការព្រមព្រៀងគ្នា ។ សូមបញ្ជាក់ដែរថាកាតព្វកិច្ចនេះមិនមែនជាកាតព្វកិច្ចដាច់ខាតនោះទេ មិនដាច់ខាតត្រង់ថា បើភាគីប្លូអេចអរ ខនសាល់ធីងមិនអាចស្វែងរកបេក្ខជនបានទេនោះ ក៏មិនមានការពិន័យអ្វីដែរ ហើយភាគីអតិថិជនក៏មិនត្រូវចំណាយទៅលើថ្លៃសេវាកម្មដែរ ។

យោងតាមចំណុចទី៨ នៃលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មជ្រើសរើសបុគ្គលិក ភាគីប្លូអេចអ ខនសាល់ធីងនឹងធ្វើការខិតខំប្រឹងប្រែងត្រួតពិនិត្យប្រវត្តិរូបរបស់បេក្ខជនតាមរយៈដំណើរការនៃការសំភាសន៍ និង ការត្រួតពិនិត្យប្រវត្តិរូបរបស់បេក្ខជន តាមរយៈសំណើរបស់ភាគីអតិថិជន ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយយើងនឹងមិនទទួលខុសត្រូវ ហើយក៏នឹងមិនធានារ៉ាប់រង រាល់ទង្វើដោយប្រយោល ឬមិនប្រយោល ឬផលអន្តរាយ ការបាត់បង់ របួសស្នាម ឬការខូតខាត ដែល

[៣៨] ចំណុចទី ១ នៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មប្រឹក្សាច្បាប់ការងារ ។
[៣៩] ចំណុចទី ២ នៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មប្រឹក្សាច្បាប់ការងារ ។

បង្ករឡើងដោយភាពមិនត្រឹមត្រូវ ឬពត៌មានក្លែងក្លាយដែលបានផ្តល់ដោយបេក្ខជន ឬពីអ្នកធានារបស់បេក្ខជន ។ ភាគីអតិថិជនមានទំនួលខុសត្រូវទាំងស្រុងចំពោះការជ្រើសរើសបេក្ខជនសម្រាប់ការងារ ។ ភាគីប៊្លូអេចអ ខនសាល់ធីងមិនចេញសងរាល់កាលៈទេសៈណាមួយដូចជាការបាត់បង់ ការខូចខាត ការពន្យាពេល ឬការចំណាយដោយភាគីអតិថិជន ឬភាពជាប់ពាក់ព័ន្ធ ផ្សេងៗ ។

អ្វីដែលសំខាន់នោះ ករណីបេក្ខជនលាឈប់ពីការងារពីក្រុមហ៊ុនភាគីអតិថិជន ឬត្រូវបានតម្រូវឱ្យលាឈប់ពីការងារ តាមការស្នើសុំរបស់ភាគីអតិថិជនក្នុងអំឡុងពេល ៣ (បី) ខែ ភាគីប៊្លូអេចអ ខនសាល់ធីងនឹងធ្វើការស្វែងរកបេក្ខជនដែលសាកសមមកជំនួសដោយឥតគិតថ្លៃសេវាកម្ម ។ បេក្ខជនដែលមកជំនួសនឹងត្រូវបានជំនួសដោយផ្តល់នូវមុខតំណែង អត្ថប្រយោជន៍ និង ការពិពណ៌នាពីការងារដូចដើមដោយមិនមានការប្រែប្រួល ។ ប្រសិនបើភាគីអតិថិជនមិនត្រូវការបេក្ខជនជំនួស ឬប្រសិនភាគីអតិថិជនស្នើសុំឱ្យភាគីប៊្លូអេចអ ខនសាល់ធីងបញ្ឈប់សកម្មភាពរើសបុគ្គលិក តម្លៃនៃការចំណាយរបស់ភាគីអតិថិជនចំនួន ៥០ (ហាសិប) ភាគរយនៃប្រាក់បៀវត្សរ៍មិនទាន់កាត់ពន្ធរបស់បេក្ខជននឹងត្រូវផ្តល់ជូនទៅឱ្យភាគីអតិថិជនជាឥណទាន ក្នុងការប្រើប្រាស់សេវាកម្មផ្សេងទៀតក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ[៩០] ។

រាល់ភារកិច្ចនីមួយៗនឹងត្រូវបានអនុវត្តក្រោមការរក្សានូវការសម្ងាត់យ៉ាងតឹងរឹង ។ ភាគីប៊្លូអេចអ ខនសាល់ធីងយល់ព្រមរក្សាការសម្ងាត់ចំពោះពត៌មានទាំងអស់របស់ភាគីអតិថិជនដោយយោងទៅតាមផែនការណ៍រើសបុគ្គលិក លើកលែងតែពត៌មានដែលត្រូវពិភាក្សា និង យល់ស្របថាជាពត៌មានចាំបាច់ដែលត្រូវពណ៌នាពីមុខតំណែងដែលបានផ្សព្វផ្សាយទៅកាន់បេក្ខជន ។

## ខ.២ កាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាប្រឹក្សាច្បាប់ការងារ

ភាគីភាគីប៊្លូអេចអ ខនសាល់ធីងនឹងផ្តល់ដំបូន្មាន ឬតំណើរការនៃប្រតិបត្តិការសេវាកម្មណាមួយរបស់ខ្លួនពេលដែលអតិថិជនត្រូវការដឹង ហើយអតិថិជនគួរតែផ្តល់ដំណឹងទៅឱ្យក្រុមហ៊ុនភាគីប៊្លូអេចអ ខនសាល់ធីងតាមអ៊ីម៉ែល ដើម្បីអះអាងអំពីសេវាកម្មដែលខ្លួនត្រូវការប្រើប្រាស់ ។ ភាគីប៊្លូអេចអ ខនសាល់ធីងនឹងទទួលខុសត្រូវសម្រាប់ការបំពេញបែបបទរាល់ការទាមទារ និង សំណួរ

[៩០] ចំណុចទី ៦ នៃស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មរើសបុគ្គលិក ។

ទាំងអស់ពីក្រសួងការងាររហូតដល់កិច្ចការត្រូវបានបញ្ចប់[៤១] ។

ភាគីប្ដីអេចអ ខនសាល់ធីងនឹងប្ដេជ្ញាចិត្តធ្វើឱ្យប្រតិបត្តិការបំពេញនូវសេវាកម្មឱ្យបានល្អសម្រាប់អតិថិជនទៅតាមរយៈពេលដែលខ្លួនបានព្រមព្រៀងជូនអតិថិជន[៤២] ។

[៤១] ចំណុចទី ៣ នៃកិច្ចព្រមព្រៀងស្ដីពីសេវាកម្មប្រឹក្សាច្បាប់ការងារ ។

[៤២] ចំណុចទី ៣ នៃកិច្ចព្រមព្រៀងស្ដីពីសេវាកម្មប្រឹក្សាច្បាប់ការងារ ។

# សេចក្តីសន្និដ្ឋាន

# និង

# ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាលើប្រធានបទ "**ពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង**" យើងសង្កេតឃើញថា ពាណិជ្ជកិច្ចចម្បងដែលក្រុមហ៊ុនកំពុងតែធ្វើ គឺការផ្តល់សេវាកម្មពិគ្រោះយោបល់ផ្នែកធនធានមនុស្ស ។ សេវាកម្មពិគ្រោះយោបល់ផ្នែកធានធានមនុស្ស ជាសេវាកម្មដែលបង្កើតឡើងដើម្បីផ្តល់ជូនដល់អតិថិជននូវសេវាកម្មជ្រើសរើសបុគ្គលិក និង សេវាកម្មប្រឹក្សាច្បាប់ការងារ ។ ម្យ៉ាងវិញទៀតយើងសង្កេតឃើញថារាល់ក្រុមហ៊ុនឯកជន អង្គការមិនមែនរដ្ឋាភិបាលសហគ្រាសង្គម ដែលត្រូវការបុគ្គលិក ហើយមិនអាចរកដោយខ្លួនឯងបាន អាចមកប្រើប្រាស់សេវាកម្មជ្រើសរើសបុគ្គលិកបានដោយធ្វើការចុះកិច្ចព្រមព្រៀងប្រើប្រាស់សេវាកម្មនេះ ។ តាមរយៈសេវាកម្មនេះ បានជួយសម្រួលដល់អតិថិជននៅក្នុងការជ្រើសរើសបុគ្គលិក ជាពិសេសទទួលបាននូវបុគ្គលិកដែលមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញការងារ ហើយអាចទទួលបានបុគ្គលិកមកបំពេញការងារបានទាន់ពេលវេលាដែលខ្លួនចង់បាន ។

វិលមកមើលសេវាកម្មប្រឹក្សាច្បាប់ការងារ ជាសេវាកម្មដែលក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង បង្កើតឡើងក្នុងគោលបំណង ផ្តល់ជូនដល់អតិថិជននូវសេវាកម្មពាក់ព័ន្ធនឹងធ្វើយ៉ាងណាឱ្យក្រុមហ៊ុនមានភាពស្របច្បាប់ទៅនឹងច្បាប់ការងារ ដែលក្នុងនោះមានសេវាកម្មដូចជា ការចុះបញ្ជីបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន សៀវភៅបើកប្រាក់ និង បញ្ជីបើកប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច ការស្នើសុំការអនុញ្ញាតពីក្រសួងការងារចំពោះការធ្វើការបន្ថែមម៉ោង និង ការស្នើសុំចំនួនហត្ថពលកម្មបរទេសជាដើម ។ ពាក់ព័ន្ធនឹងសេវាកម្មប្រឹក្សាច្បាប់ការងារនេះបានផ្តល់អត្ថប្រយោជន៍ជូនអតិថិជននៅក្នុងការធ្វើឱ្យក្រុមហ៊ុននោះមានភាពស្របច្បាប់ ដោយហេតុថាម្ចាស់ក្រុមហ៊ុន ឬ តំណាងក្រុមហ៊ុនមួយចំនួនមិនបានយល់ដឹងអំពីបញ្ហានេះ ហើយក៏ធ្វើឱ្យចំណេញពេលវេលានៅក្នុងដំណើរការរត់ការឯកសារផ្សេងៗផងដែរ ។

ការបង្កើតកិច្ចសន្យា គឺជារឿងដែលសំខាន់សម្រាប់ការធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ព្រោះថាបានបង្កើតនូវចំណងគតិយុត្តិដ៏រឹងមាំមួយសម្រាប់ចងនូវសិទ្ធិ និង កាតព្វកិច្ចរបស់ភាគី ។ ការផ្តល់សេវាកម្មរបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ជាទូទៅត្រូវធ្វើឡើងតាមរយៈកិច្ចព្រមព្រៀងស្តង់ដាររបស់ខ្លួនមួយជាមួយនឹងអតិថិជន ដោយផ្នែកស្តង់នៃកិច្ចព្រមព្រៀងនេះក៏អាចប្រែប្រួលនូវ

លក្ខខណ្ឌមួយចំនួនអាស្រ័យទៅលើការព្រមព្រៀងរបស់ភាគីផងដែរ ។ លើសពីនេះទៅទៀត ការព្រមព្រៀងនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់ភាគីទាំងសងខាងទើបកិច្ចសន្យានេះមានសុពលភាព ។

## ២. ការផ្តល់អនុសាសន៍

ការសិក្សាស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញថា ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងមានបញ្ហាមួយចំនួនបានកើតឡើងចំពោះការធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុននេះ ។ បញ្ហាដែលធ្លាប់បានកើតមាននោះមានដូចជា ភាគីអតិថិជនមិនព្រមបង់ប្រាក់តាមកាលកំណត់លើការប្រើប្រាស់សេវាកម្ម ការបដិសេធទទួលយកបេក្ខជនដែលអតិថិជនបានសម្ភាសន៍ថាជាប់ហើយឱ្យចូលធ្វើការ ដោយហេតុផលមិនសមរម្យ និង ការមិនផ្តល់ពត៌មាន ឬឯកសារតម្រូវឱ្យបានគ្រប់គ្រាន់ និង ទាន់ពេលវេលាកំណត់ ហើយការកើតមានបញ្ហាទាំងនេះក៏ដោយសារតែភាពទុកចិត្តរបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងផងដែរ ។

ដើម្បីឆ្លើយតបបញ្ហាខាងលើនេះក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងមិនគួរទុកចិត្តភាគីអតិថិជនពេកទេ ។ អ្វីដែលគួរធ្វើគឺការបង្កើតឱ្យមានកិច្ចសន្យា ពិសេសកិច្ចសន្យាស្តីពីសេវាកម្មជ្រើសរើសបុគ្គលិកគួរចែងបន្ថែមទៀតអំពីកាតព្វកិច្ចរបស់ភាគីអតិថិជន និង ការផាកពិន័យចំពោះការមិនអនុវត្តកាតព្វកិច្ចដែលបានព្រមព្រៀងរវាងភាគីទាំងសងខាង ។

បញ្ហាគួរឱ្យកត់សម្គាល់មួយទៀតនោះ គឺសម្រាប់ការធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនមួយប្រៀបធៀបទៅនឹងវិធានគតិយុត្តិជាធរមានរបស់កម្ពុជានាពេលបច្ចុប្បន្ននេះ យើងអាចនិយាយបានថានៅមានភាពខ្វះខាតនៅឡើយ ។ នៅមានភាពខ្វះខាតដោយសារការធ្វើពាណិជ្ជកិច្ចនាពេលបច្ចុប្បន្នមានភាពសម្បូរបែបដែលធ្វើឱ្យវិធានច្បាប់មិនអាចតាមទាន់ ។ គួរយ៉ាងការធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីងជាប្រភេទនៃការធ្វើពាណិជ្ជកិច្ចទាក់ទងសេវាកម្ម ហើយបើយើងក្រឡេកមើលវិធានច្បាប់វិញ មានវិធានច្បាប់ពាណិជ្ជកម្មតិចតួចដែលចែងអំពីពាណិជ្ជកិច្ចប្រភេទនេះ ។ ដើម្បីបំពេញដល់ភាពខ្វះខាតទាំងនេះ ព្រះរាជាណាចក្រកម្ពុជាគួរតាក់តែងវិធានច្បាប់បន្ថែមទៀតដែលពាក់ព័ន្ធនឹងពាណិជ្ជកិច្ចប្រភេទនេះ ។ លើសពីនេះទៅទៀតការមានវិធានច្បាប់គ្រប់គ្រាន់នឹងជួយឱ្យការធ្វើពាណិជ្ជកិច្ចមានភាពរីកចម្រើន ជាពិសេសជួយជម្រុញឱ្យមានការធ្វើវិនិយោគទុនកាន់តែច្រើនមកប្រទេសកម្ពុជា ។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រុមហ៊ុនប៊្លូអេចអ ខនសាល់ធីងនៅតែបន្តផ្តល់សេវាកម្មដែលមានភាពល្អប្រសើរនេះទៅកាន់អតិថិជន និង ពង្រីកបន្ថែមនូវសកម្មភាពពាណិជ្ជកិច្ចរបស់ខ្លួនដើម្បីជួយលើកកម្ពស់សេដ្ឋកិច្ចកម្ពុជា និង បង្កើតការងារឱ្យកាន់តែច្រើនសម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

# ឯកសារយោង

# ឯកសារយោង

## I. ក្រម

១. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ។

## II. ច្បាប់

២. ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្មឆ្នាំ ១៩៩៥ និង ច្បាប់ស្តីពីវិសោធនកម្មឆ្នាំ ១៩៩៩ ។

៣. ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ។

៤. ច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧ ។

៥. សេចក្តីព្រៀងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្មឆ្នាំ ២០១១ ។

## III. អនុក្រឹត្យ

៦. ក្រឹត្យច្បាប់ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យាលេខ ៣៨ ក្រ.ចឆ្នាំ ១៩៨៨ ។

## IV. សៀវភៅដែលជាស្នាដៃរបស់អ្នកនិពន្ធខ្មែរ

៧. សិក្ខាប័ននីតិពាណិជ្ជកម្មរបស់លោកសាស្ត្រាចារ្យ **ជិន វណ្ណារ៉ា** បោះពុម្ពឆ្នាំ ២០១៣ ។

៨. សេចក្តីពន្យល់មាត្រានីមួយៗក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១០ ។

## V. ឯកសាររបស់ក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង

៩. លក្ខន្តិកៈក្រុមហ៊ុន ។

១០. ស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មរើសបុគ្គលិក ។

១១. កិច្ចព្រមព្រៀងស្តីពីសេវាកម្មប្រឹក្សាច្បាប់ការងារ ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី ១

# ស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មរើសបុគ្គលិក

# ស្តង់ដារលក្ខខណ្ឌនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មរើសបុគ្គលិក

លក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះគឺធ្វើឡើងរវាងក្រុមហ៊ុនប្លូអេចអ ខនសាល់ធីង ដែលសំដៅ ជាភាគី "ប្លូអេចអរខន់សាល់ធីង" ជាមួយ "ក្រុមហ៊ុន" ដែលសំដៅជាភាគី "អតិថិជន" ហើយសន្មត់ ថាបានយល់ព្រមពីភាគីអតិថិជនតាមរយៈការចុះហត្ថលេខាយល់ស្របទៅលើលក្ខខណ្ឌ នៃកិច្ចព្រម ព្រៀង។ លក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះមានសុពលភាពដរាបណាដែលមានការកែប្រែ ឬមានការ ផ្តល់នូវការសរសេរជាលាយលក្ខណអក្សរត្រឹមត្រូវ និងយល់ព្រមដោយភាគីទាំងសងខាងទៅលើ លក្ខណដែលត្រូវផ្លាស់ប្តូរ។

## ១.ការគណនាទៅលើតំលៃជំនាញការណ៍

ភាគីអតិថិជនមិនចំណាយទៅលើតំលៃជំនាញការណ៍របស់យើងនោះទេ ប្រសិនបើមុខតំណែងដែលភាគីអតិថិជនធ្វើការជ្រើសរើសមិនបានបំពេញដោយបេក្ខជនពីភាគីប្លូអេចអ ខនសាល់ធីង។ មិនមានការតំរូវអោយចំណាយពីភាគីអតិថិជនដោយគ្រាន់តែការសាកសួរពត៌ មាន ឬគ្រាន់តែធ្វើការចុះហត្ថលេខាទៅលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។

តំលៃជំនាញការណ៍របស់យើងត្រូវបានគណនាដោយគិតទៅលើប្រាក់បៀវត្សរ៍ដោយមិនទាន់កាត់ពន្ធរបស់បេក្ខជនបន្ទាប់ពីការសាកល្បងការងារ លើកលែងតែភាគីទាំងពីរមានការ ព្រមព្រៀងគ្នាទៅលើប្រការណាមួយដោយឡែក។

តំលៃជំនាញការណ៍របស់យើងនឹងត្រូវគិតថ្លៃហើយភាគីអតិថិជនមានកាតព្វកិច្ចទូទាត់សងនៅពេលដែលបេក្ខជនចាប់ផ្តើមការងារ មិនមែននៅពេលដែលបេក្ខជនចប់ការសាកល្បងការងារ នោះទេ។

## ២.និតិវិធីនៃការទូទាត់សង

នាពេលដែលកិច្ចសន្យាការងារ ឬលិខិតផ្តល់ជូនការងារ ឬទំរង់នៃកិច្ចសន្យាផ្សេងៗ ដែលផ្តល់ជូន

Unofficial Translation

បេក្ខជន ភាគីអតិថិជនត្រូវយល់ព្រមផ្តល់ដំណឹងដល់ភាគីប្លូអេចអរ ខន់សាល់ធីង ភ្លាម តាមរយៈ សារ ឬ សំបុត្រដោយបញ្ជាក់ពីឈ្មោះបេក្ខជនដែលត្រូវជួល មុខតំណែង ប្រាក់ បៀវត្សរ៍មិនទាន់កាត់ ពន្ធ ដែលមានចែងក្នុងកិច្ចសន្យា និងថ្ងៃចាប់ផ្តើមធ្វើការ។

វិក័យបត្រ័នឹងត្រូវធ្វើជូនទៅភាគីអតិថិជននៅពេលដែលបេក្ខជនបានអះអាងដោយបានដាក់លិខិតលាឈប់ពីការងារ និងបានចុះហត្ថលេខាលើកិច្ចសន្យាការងារ ឬ លិខិតផ្តល់ជូនការងារ ពីភាគីអតិថិជន។

ការទូទាត់សងទៅលើតំលៃជំនាញការណ៍ជាកាតព្វកិច្ចរបស់ភាគីអតិថិជនដែលត្រូវទូទាត់ក្នុងរយៈ ពេល ១៥ថ្ងៃនៃកាលបរិច្ឆេទលើវិក័យបត្រ។

ការចំណាយទៅលើថ្លៃផ្សព្វផ្សាយឬថ្លៃផ្សេងៗទៀតក៏ជាកាតព្វកិច្ចរបស់ភាគីអតិថិជនដែលត្រូវទូទាត់ រយៈពេល ១៥ ថ្ងៃ នៃកាលបរិច្ឆេទលើវិក័យបត្រ័ លើកលែងតែភាគីទាំងពីរមាន ការព្រមព្រៀងគ្នាទៅលើប្រការណាមួយដោយឡែក។

**៣.ពត៌មានពីភាគីអតិថិជន**

ប្រសិនបើអតិថិជនមានមុខតំណែងត្រូវជ្រើសរើស ហើយភាគីអតិថិជនចង់ប្រើប្រាស់សេវា កម្មរបស់យើងដើម្បីផ្តល់ជូនបេក្ខជនដែលមានសមត្ថភាព យើងតំរូវអោយភាគីអតិថិជនផ្តល់ នូវពត៌មានចំពោះមុខតំណែងនោះដូចជា៖

1. ឈ្មោះមុខតំណែង, ការពិពណ៌នាពីការងារ
2. ប្រាក់បៀវត្សរ៍នៃមុខតំណែង
3. ថ្ងៃស្នើសុំក្នុងការចាប់ផ្តើមការងារ

Unofficial Translation

## ៤.ប្រភពនៃការស្វែងរកបេក្ខជន

**ប្រភពស្វែងរក:** ភាគីប្លូអេចអ ខនសាល់ធីងនឹងស្វែងរកបេក្ខជនដោយប្រើប្រាស់នូវការ ស្រាវជ្រាវពីប្រភពផ្សេងៗដើម្បីកំណត់បាននូវបេក្ខជនប្រកបដោយសមត្ថភាព និងទេព កោសល្យ ។ ដោយទាំងនេះរួមមាន: ការស្វែងរកផ្ទាល់តាមរយ:ប្រពន្ធ័ផ្ទុកទន្និន័យបេក្ខជន ការទំនាក់ទំនងដោយផ្ទាល់ ទីផ្សារការងារ បណ្តាញសង្គម និង ជំនាញវិជ្ជាជីវ:។

**ការផ្សព្វផ្សាយ:** នៅពេលដែលភាគីអតិថិជនចង់ធ្វើការផ្សព្វផ្សាយមុខតំណែងតាមរយ: ភាគីប្លូអេចអ ខនសាល់ធីង យើងគួរជួយរៀបចំនូវការផ្សព្វផ្សាយការងារ ហើយនាពេលដែល ការរៀបចំរួចរាល់ យើងនឹងដាក់ជូនទៅភាគីអតិថិជនដើម្បីពិនិត្យ និង យល់ស្រប។ នាពេលនោះដែរ យើងនឹងផ្តល់ដំណឹង ជូនភាគីអតិថិជនចំពោះថ្លៃផ្សេងៗដែលទាក់ទងនឹង ការផ្សព្វផ្សាយ។

## ៥.និតិវិធីនៃការជ្រើសរើសបុគ្គលិក

ជាទូទៅយើងនឹងផ្តល់ជូនភាគីអតិថិជននូវបេក្ខជន ដែលបានជ្រើសរើសចុងក្រោយ ប្រហែល ជាមួយសប្តាហ៍ បន្ទាប់ពីទទួលបានពត៌មានចាំបាច់ទាក់ទងនឹងមុខតំណែង និង ភាគីអតិថិជន ក៏មានសិទ្ធិក្នុងស្វែងរកបេក្ខជន។ យោងទៅតាមតំរូវការរបស់ភាគីអតិថិជន និងស្ថិតលើ ការពិចារណាពីលក្ខណ្ឌ ទីផ្សារការងារ យើងនឹងអាចបន្ថយ ឬបង្កើនរយ:ពេលនៃការផ្តល់ជូន បេក្ខជន។

ការប្រើប្រាស់វិធីនៃការស្វែងរកបេក្ខជនរបស់យើងតាមរយ:ប្រភពត្រឹមត្រូវផ្សេងៗទាំងអស់ដើម្បីកំណត់បាននូវបេក្ខជនប្រកបដោយទេពកោសល្យ និង ប្រកបដោយសមត្ថភាព ដែលទាំង នេះរួមមាន៖ ការស្វែងរកផ្ទាល់តាមរយ:ប្រពន្ធ័ផ្ទុកទន្និន័យអតិថិជន ការទំនាក់ទំនងដោយ ផ្ទាល់ទីផ្សារ ការងារបណ្តាញសង្គម និង ជំនាញវិជ្ជាជីវ:។ ខណ:ពេលជាមួយគ្នានេះ ដែរ ការប្រើនូវឪកាសនេះដើម្បី ណែនាំបេក្ខជនអំពីអាជីវកម្ម និងសកម្មភាព របស់ភាគីអតិថិជន។

Unofficial Translation

អញ្ជើញបេក្ខជនដែលបានជ្រើសរើសមកសំភាសន៍ជុំទី១ ឬ អាចសំភាសន៍ជុំទី១ ប្រសិន បើចាំបាច់ធ្វើការត្រួតពិនិត្យជាមួយនឹងអ្នកផានា ទៅតាមការសំនូមពររបស់ភាគីអតិថិជន ជំហ៊ានបន្ទាប់ ធ្វើការកំណត់នូវបេក្ខជនដ៏ល្អបំផុតដែលជាសក្កដានុពលភាពសំរាប់ មុខ តំណែង។

រៀបចំប្រវត្តិរូបសង្ខេបក្នុងទំរង់បែបបទផ្លូវការហើយបញ្ជូនអោយភាគីអតិថិជន ដើម្បីធ្វើការ ត្រួតពិនិត្យនៅពេលភាគីអតិថិជនបញ្ជាក់ចង់ធ្វើការសំភាសន៍ជាមួយនឹងបេក្ខជន យើងនឹង រៀបចំកាលវិភាគណាត់ជួបសំភាសន៍ជូនដល់ភាគីអតិថិជននៅការិយាល័យឬក្រុមហ៊ុន និង ដើម្បីជួយភាគីអតិថិជនក្នុងការជ្រើសរើសបេក្ខជនចុងក្រោយ។

**៦.ការជំនួស**

ករណីបេក្ខជនលាឈប់ពីការងាររបស់ភាគីអតិថិជន ឬត្រូវបានតំរូវអោយលាឈប់ពីការងារ តាមការស្នើសុំរបស់ភាគីអតិថិជនក្នុងរយៈពេល៣ខែ ភាគីប៊្លូអេចអ ខនសាល់ធីងនឹងធ្វើ ការស្វែងរកបេក្ខជនដែលសាកសមមកជំនួសដោយឥតគិតថ្លៃសេវាកម្ម។ បេក្ខជនដែលមកជំនួស នឹងត្រូវបានជំនួសដោយផ្តល់នូវមុខតំណែង អត្ថប្រយោជន៍ និង ការពិពណ៌នាពីការងារដូចដើម ដោយមិន មានការប្រែប្រួល។

ករណីដោយមានការផ្សព្វផ្សាយពីដំណឹងជ្រើសរើសបុគ្គលិកបន្ថែមទៀត ភាគីអតិថិជនត្រូវមានកាតព្វកិច្ចចំណាយទៅលើការចំណាយនោះបន្ថែមទៀត។

ប្រសិនបើភាគីអតិថិជនមិនត្រូវការបេក្ខជនជំនួស ឬ ប្រសិនភាគីអតិថិជនស្នើសុំអោយភាគីប៊្លូអេចអ ខនសាល់ធីង បញ្ឈប់សកម្មភាពរើសបុគ្គលិក តំលៃនៃការចំណាយរបស់ភាគីអតិថិជនចំនួន ៥០ភាគរយនៃប្រាក់បៀវត្សរ៍មិនទាន់កាត់ពន្ធរបស់បេក្ខជននឹងត្រូវផ្តល់ជូនទៅអោយភាគីអតិថិជនជាឥណទានក្នុងការប្រើប្រាស់សេវាកម្មផ្សេងទៀតក្នុងរយៈពេល៦ខែ។

Unofficial Translation

## ៧.លក្ខណដែលមិនមានការពង្រីកលើការគ្របដណ្តប់បន្ថែមទៅលើភាគីអតិថិជន

ការផ្លាស់ប្តូរកំណែទំរង់ ការរៀបចំឡើងវិញ ការផ្លាស់ប្តូរថ្នាក់គ្រប់គ្រង ឬម្ចាស់កម្មសិទ្ធិ ឬកត្តាផ្សេងទៀតដែលមិនពាក់ពន្ធ័នឹងការបំពេញការងាររបស់និយោជិក។

## ៨.បំណុល

ភាគីប្លូអេចអ ខនសាល់ធីងនឹងធ្វើការខិតខំប្រឹងប្រែងត្រួតពិនិត្យប្រវត្តិរូបរបស់បេក្ខជនតាមរយៈ ដំណើរការនៃការសំភាសន៍ និងការត្រួតពិនិត្យប្រវត្តិរូបរបស់បេក្ខជនតាមរយៈសំណើរបស់ភាគី អតិថិជន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ យើងនឹងមិនទទួលខុសត្រូវ ហើយក៏នឹងមិនធានារ៉ាប់រង រាល់ទង្វើដោយប្រយោល ឬមិនប្រយោលឬ ផលអន្តរាយ ការបាត់បង់ របួសស្នាម ឬការខូតខាត ដែលបង្ករឡើងដោយភាពមិនត្រឹមត្រូវ ឬពត៌មានក្លែងក្លាយដែលបានផ្តល់ដោយបេក្ខជន ឬ ពីអ្នក ធានារបស់បេក្ខជន។ ភាគីអតិថិជនមានទំនួលខុសត្រូវទាំងស្រុងចំពោះការជ្រើសរើសបេក្ខជនសំរាប់ ការងារ។

ភាគីអតិថិជននឹងត្រូវទទួលខុសត្រូវលើការងារ និងលិខិតអនុញ្ញាតផ្សេងៗសំរាប់ការរៀបចំលើការ ត្រួតពិនិត្យសុខភាពដោយបានតំរូវដោយការអនុវត្តតាមច្បាប់។

ភាគីប្លូអេចអ ខនសាល់ធីងមិនចេញសងរាល់កាលៈទេសៈណាមួយដូចជាការបាត់ប់ ការខូចខាត ការពន្យាពេល ឬការចំណាយដោយភាគីអតិថិជនឬភាពជាប់ពាក់ពន្ធ័ផ្សេងៗ។

## ៩.ពត៌មានសំងាត់

រាល់ភារកិច្ចនិមួយៗនឹងត្រូវបានអនុវត្តក្រោមការរក្សានូវការសំងាត់យ៉ាងតឹងរឹង។ ភាគីភាគីប្លូអេចអ ខនសាល់ធីងយល់ព្រមរក្សាការសំងាត់ចំពោះពត៌មានទាំងអស់របស់ភាគីអតិថិជនដោយយោងទៅ តាមផែនការណ៍រើសបុគ្គលិក លើកលែងតែពត៌មានដែលត្រូវពិភាក្សា និងយល់ស្របថាជាពត៌មាន

ចាំបាច់ដែលត្រូវពណ៌នាពីមុខតំណែងដែលបានផ្សព្វផ្សាយទៅកាន់បេក្ខជន។ ភាគីអតិថិជនយល់ស្របរក្សាការសំងាត់ពីពតិមានអំពីបេក្ខជនដែលត្រូវបង្ហាញជូនភាគីអតិថិជនពីភាគីប្លូអេចអ ខនសាល់ធីង ហើយមិនត្រូវប្រកាសអោយភាគីទី៣ផ្សេងទៀតដឹងពីលក្ខណ្ឌទាំងអស់នៅក្នុងផ្នែក ណាមួយនៃកិច្ចសន្យានេះនោះទេ។

## ១០.ការផ្តល់សិទ្ធិនៃការប្រើប្រាស់សេវាកម្ម

ខ្ញុំ តំណាងអោយក្រុមហ៊ុននៃភាគីអតិថិជនរបស់ក្រុមហ៊ុន បានយល់ច្បាស់ និងព្រមព្រៀងទៅតាមលក្ខណនៅក្នុងកិច្ចសន្យានេះ ហើយព្រមធ្វើការ សហការជាមួយភាគីប្លូអេចអ ខនសាល់ ធីង ដើម្បីស្វែងរកបេក្ខជនដែលសាកសមទៅតាមការ ពិភាក្សាគ្នា។ ខ្ញុំក៏ត្រូវបានទទួលស្គាល់ថា ជាតំណាង អោយក្រុមហ៊ុននៃភាគីអតិថិជន ខ្ញុំមានសិទ្ធិក្នុង ការចុះហត្ថលេខាក្នុងនាមជាក្រុមហ៊ុនដែលបាន បញ្ជាក់ខាងលើ។

**ជំនួស និង តំណាងអោយ** **កាលបរិច្ឆេទ**

**ក្រុមហ៊ុន**

**ជំនួស និង តំណាងអោយ** **កាលបរិច្ឆេទ**

**ក្រុមហ៊ុនប្លូអេចអ** **ខនសាល់ធីង**

Unofficial Translation

# ឧបសម្ព័ន្ធទី ២

## កិច្ចព្រមព្រៀងស្តីពីសេវាកម្មប្រឹក្សាច្បាប់

## ការងារ

## TERMS OF AGREEMENT ON COMPLIANCE SERVICES

These terms of Agreement are between **blueHR Consulting**, hereinafter referred to as "blueHR Consulting", a company duly incorporated under the laws of Cambodia with its registered office at 73bg, St. 360, Sankat Boeung KengkangIII, Khan Chamkamorn, Phnom Penh, Cambodia, and ## hereafter referred to as "the Client", a company duly incorporated under the laws of Cambodia with its office at Building ##, Cambodia and is deemed to be accepted by the client upon signature of the Terms of Agreement. These Terms of Agreement are valid until such time as revised or formal written communications are provided and agreed upon by both parties that Terms have changed.

This agreement details the terms and conditions of compliance services to be provided by blueHR Consulting to the client. The agreement shall be valid starting from the month of **# to #** within upon mutual signing by both parties of this Agreement.

### 1. Our professional Fees

The client shall confirm the deadline to provide all required documents and completed forms to blueHR consulting. If the client fails to provide the mentioned documents within the agreed deadline, blueHR Consulting has the right to charge additional expenses on the additional time spent.

blueHR Consulting will not be responsible any delay or late caused by The Client.

### 2. Our Term of Payment

Payment is due within seven calendar days of the receipt of the invoice by the client

### 3 Our Services

blueHR Consulting will advise or process any compliance items when the client needs, and the client shall inform to blueHR Consulting's team by e-mail to confirm on the services-ordered.

blueHR Consulting has a professional team with the right skill, ability, experience and commitment to meet the client needs.

blueHR Consulting will be responsible for completing any requirement and handling any queries from MOLVT until the tasks are completed.

The tasks shall be deemed to be completed upon the final approval from the MOLVT and the delivery of all output to the Client.

**4. The Labor Compliance Workflow and Guarantee**

blueHR Consulting shall commit to make compliance services done for the “Client” in the period that is stated by each services item in the **#.**

**5. Amendments.**

Any amendment to this agreement shall be agreed in writing by both the client and blueHR Consulting, and shall refer to the agreement.

**6. Governing Law**

This agreement shall be governed by and construed in accordance with the laws of Cambodia.
The parties hereby fully understand and accept the agreement. The signatories acknowledge that each is a company representative and has the authority to sign agreements of the Client.
All disputes, controversies or claims in relation to this agreement shall be submitted to the Court of Cambodia. All costs and expenses in respect of the court shall be borne by the non-prevailing party.

I, the Client Company Representative of client. hereby fully understand and accept the above Term of Agreement. I also acknowledge that as the Client Company Representative I have authority to sign agreements on behalf of the Company state above.

___________________ ______________________

For and On Behalf of client Date

______________________ _______________________

For and On Behalf of blueHR Consulting Date